**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Universite Royale de Droit et des Sciences Economiques

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ នៅខេត្តកំពង់ចាមបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **អ៊ុន ច័ន្ទរក្សា**

**ទង់ សំអុល**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឌី ពុទ្ធារ៉ា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំបញ្ចប់សិក្សា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**
Universite Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ
# នៅខេត្តកំពង់ចាមបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **អ៊ុន ច័ន្ទរក្សា**
**ខង់ សំអុល**

សាស្រ្តាចារ្យណែនាំ
**បណ្ឌិត ឌី ពុទ្ធារ៉ា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណ:**
ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំបញ្ចប់សិក្សា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **អ៊ុន ច័ន្ទរក្សា** និង **វង់ សំអុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី២២ផ្នែករដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២១-២០២២។

យើងខ្ញុំទាំងពីរនាក់សូមគោរពថ្លែងអំណរគុណនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

- ❖ **លោកឪពុក និង អ្នកម្តាយ** ទាំងពីរដែលលោកបានផ្តល់កំណើត និងបានផ្គត់ផ្គង់លើការសិក្សារបស់កូនទាំងពីរនាក់ក្នុងរយៈពេល៤ឆ្នាំមកនេះដោយលោកបានអប់រំ ទូន្មាន ប្រៀនប្រដៅប្រកបដោយទឹកចិត្តព្រហ្មវិហាធម៌។ លោកអ្នកមានគុណបានខិតខំស្វែងរកថវិការ ក្នុងការឧបត្ថម្ភកូនដើម្បីឱ្យកូនបាននូវចំណេះដឹងនិងពុះពារប្រឈមមុខ និងរាល់ទុកលំបាកគ្រប់បែបយ៉ាង ក៏ដូចជាផ្តល់នូវកម្លាំងចិត្តដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ។
- ❖ **ឯកឧត្តម បណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ និងសាកលវិទ្យាល័យធិការរងព្រឹទ្ធបុរស ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានរៀបចំឱ្យសាកលវិទ្យាល័យ មានដំណើរការប្រកបដោយភាពជោគជ័យដូចជាការខិតខំសម្រួលការសិក្សារបស់និស្សិត ដោយយកចិត្តទុកដាក់ក្នុងការបង្រៀនដោយមិនខ្លាចនឿយហត់ និងដើម្បីជាស្ពានក្នុងការពង្រីកសមត្ថភាពចំណេះដឹងរបស់សិស្ស។
- ❖ ខ្ញុំបាទទាំងពីរ សូមធ្វើការគោរពយ៉ាងធំធេងបំផុតជូនចំពោះសាស្ត្រាចារ្យណែនាំ **បណ្ឌិត ឌី ពុទ្ធារ៉ា** ជាសាស្ត្រចារ្យក្នុងការដឹកនាំសារណារបស់យើងខ្ញុំទាំងពីរនាក់ ដោយលោកគ្រូសាស្ត្រចារ្យពុំខ្លាចនឿយហត់ក្នុងការអប់រំដល់យើងខ្ញុំ លោកតែងតែបង្ហាញ និងចង្អុលផ្លូវដោយបានផ្តល់នៅការជជែកពិភាក្សាយ៉ាងកក់ក្តៅបំផុត និងបានបង្ហាត់បង្រៀនដោយការយកចិត្តទុកដាក់ ក្នុងការសិក្សាស្រាវជ្រាវ ចងក្រង សរសេរអត្ថបទសារណានេះឡើងរហូតបានបញ្ចប់ជាស្ថាពរ។

ជាកិច្ចបញ្ចប់ ខ្ញុំបាទទាំងពីរនាក់សូមប្រសិទ្ធពរជ័យជូនដល់ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរងព្រឹទ្ធបុរស និងសាស្ត្រចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឱ្យមានសុខភាពល្អទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ក្នុងការសិក្សារអស់រយៈពេលពេល៤ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២ បន្ទាប់ពីបានឆ្លងកាត់ការសិក្សាថ្នាក់បញ្ញាបត្ររដ្ឋបានសាធារណៈនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី១៥ ក្រុមP4A5 យើងខ្ញុំទាំងពីរនាក់ពិតជាមានសំណាងណាស់ដែលទទួលបាននូវ ចំណេះដឹងប្រកបដោយ គុណភាពសមត្ថភាពល្អ ដោយផ្អែកលើទ្រឹស្តី បទពិសោធរបស់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀន និងយកចិត្តទុកដាក់ និងលើកទឹកចិត្តឱ្យកាន់តែមានកម្លាំងចិត្តក្នុងការសិក្សារៀនសូត្រ ដែលនាំឱ្យយើងខ្ញុំទាំងពីរទទួលបាននូវលទ្ធផលល្អមកដល់សព្វថ្ងៃនេះ។ ដូចនេះដើម្បីវាយតម្លៃលើចំណេះដឹងរបស់ពួកយើងខ្ញុំបាទទាំងពីរបានជ្រើសរើសយកប្រធានបទមួយស្តីពី **ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ នៅខេត្តកំពង់ចាមបច្ចុប្បន្ន** មកធ្វើការសិក្សាស្រាវជ្រាវចងក្រងធ្វើជាសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បញ្ញាបត្ររដ្ឋបាលសាធារណៈ។

បានជាយើងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទនេះ មកសរសេរសារណាបញ្ចប់ការសិក្សាដោយហេតុថា យើងខ្ញុំមានគោលបំណងចង់ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ក្នុងការគ្រប់គ្រងរដ្ឋបាលឱ្យកាន់តែច្បាស់លាស់ ពីការប្រែប្រួលស្ថានភាពរដ្ឋបាល តាមស្ថាប័ន ឬ ក្រសួង ព្រមទាំងនីតិវិធីដែលអនុវត្តទៅលើការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ធ្វើឱ្យមានប្រសិទ្ធិភាពប្រសើរឡើងវិញក្នុងប្រទេសកម្ពុជាយើង។សារណាបញ្ចប់ការសិក្សាមួយនេះ គឺជាសមិទ្ធផលមួយ ដែលយើងខ្ញុំទាំងពីរនាក់បានខិតខំសិក្សាស្រាវជ្រាវការវិភាគវែកញែកនិងប្រៀបធៀបពីការគ្រប់គ្រងរដ្ឋបាលដោយការយកចិត្តទុកដាក់បំផុត ដើម្បីពង្រីកនូវចំណេះដឹង បន្ថែមទៀត ដែលត្រូវតែលើកយកមកបង្ហាញ និងការបង្ហាញនៅក្នុងឯកសារនេះ។

បើមានការខ្វះខាតត្រង់ចំណុចណាមួយ យើងខ្ញុំទាំងពីរនាក់រងចាំទទួលការរិះគន់ទាំងឡាយក្នុងន័យស្ថាបនាពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយរាល់កំហុសខុសឆ្គងដោយអចេតនានូវ ពាក្យពេជ្រ វគ្គឃ្លា វេយ្យាករណ៍ អក្ខរក្រម ដើម្បីជួយកែលំអរសៀវភៅនេះកាន់តែល្អនិងមានភាពសុក្រិត។ សូមគោរពជូនពរដល់ មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យនិងមិត្តនិស្សិតទាំងអស់ ឱ្យមានសេចក្តីសុខ និងសំណាងល្អគ្រប់ពេលវេលាជោគជ័យលើការសិក្សា និងការងារនានា។

## មាតិកា

ទំព័រ

**សេចក្តីផ្តើម**........................................................................................................១

**ជំពូកទី១**

**រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ**

**១.១. ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា**......................................................................................៦

១.១.១. និយមន័យវិមជ្ឈការ..........................................................................................៦

១.១.២. មុខងារវិមជ្ឈការ..............................................................................................៧

១.១.៣. លក្ខណៈពិសេសនៃវិមជ្ឈការ...............................................................................៧

១.១.៤. ទម្រង់ផ្សេងៗនៃវិមជ្ឈការ....................................................................................៧

១.១.៤.១. វិមជ្ឈការរដ្ឋបាល........................................................................................៨

១.១.៤.២. វិមជ្ឈការបច្ចេកទេស....................................................................................៨

១.១.៤.៣. វិមជ្ឈការហិរញ្ញវត្ថុ និងសារពើពន្ធ....................................................................៨

១.១.៤.៤. វិមជ្ឈការនយោបាយ និងប្រជាធិបតេយ្យ.............................................................៩

**១.២. ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**..........................................................................៩

១.២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ...................................៩

១.២.២. សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ......................................................៩

**១.៣. គោលការណ៍នៃអភិបាលកិច្ចល្អ**..................................................................................១០

**ជំពូកទី២**

**ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ**

**២.១. ស្ថានភាពព័ត៌មានទូទៅ**..........................................................................................១៤

២.១.១. ស្ថានភាពភូមិសាស្ត្រ.........................................................................................១៤

**២.២. ការរៀបចំរដ្ឋបាលស្រុក ខណ្ឌ**...................................................................................១៥

២.២.១. រចនាសម្ព័ន្ធការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ...........................................................១៥

២.២.២. ក្រុមប្រឹក្សា........១៥

២.២.៣. សិទ្ធិអំណាចក្រុមប្រឹក្សាស្រុក........១៥

២.២.៤. របៀបរបបការងាររបស់ក្រុមប្រឹក្សាស្រុក........១៦

២.២.៥. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក........១៧

**២.៣. គណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ**........១៨

២.៣.១. តួនាទី និងភារកិច្ចរបស់គណៈអភិបាលស្រុក........១៩

២.៣.២. របៀបរបបការងាររបស់គណៈអភិបាលស្រុក........២១

**២.៤. មុខងាររបស់រដ្ឋបាលស្រុក**........២៣

**២.៥. ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក**........២៤

**២.៦. ការបង្កើតការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**........២៤

២.៦.១ តួនាទី ភារកិច្ចរបស់ការិយាល័យរបស់ប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ........២៥

២.៦.២. សិទ្ធិអំណាចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ........២៥

**២.៧. ទំនាក់ទំនងរវាងរដ្ឋបាលស្រុក និងរដ្ឋបាលខេត្ត**........២៦

**២.៨. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក**........២៧

**២.៩. របបហិរញ្ញវត្ថុរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**........២៧

២.៩.១. ប្រភពចំណូល........២៨

២.៩.២. ការិយាល័យចំណុះស្រុកបាធាយ........២៨

២.៩.៣. ការគ្រប់គ្រងធនធានមនុស្សរដ្ឋបាលស្រុកបាធាយ........៣២

២.៩.៤. ផែនការអភិវឌ្ឍប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល........៣៣

២.៩.៥. គោលការណ៍សំខាន់ៗនៃការកសាងផែនការអភិវឌ្ឍប្រាំឆ្នាំ........៣៣

២.៩.៦. ដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍប្រាំឆ្នាំរបស់រដ្ឋបាលស្រុកបាធាយ........៣៤

២.៩.៧. ដំណើរការរៀបចំ និង កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល........៣៥

២.៩.៨. ថវិការបស់រដ្ឋបាលស្រុក........៣៥

## ជំពូកទី៣

## បញ្ហាប្រឈម និងដំណោះស្រាយ

**៣.១. សមិទ្ធិផលស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម**........................................................៣៧

៣.១.១. ស្ថានភាពសេដ្ឋកិច្ច.........................................................................................................៣៧

៣.១.២. ស្ថានភាពសង្គមកិច្ច.......................................................................................................៤១

៣.១.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន.................................៤៦

៣.១.៤. ស្ថានភាពគ្រប់គ្រងរដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ..............................................៤៨

**៣.២. សង្ខេបប្រភពមូលនិធិឆ្នាំ ២០២១**..........................................................................................៥៣

៣.២.១. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល ឆ្នាំ ២០២១.........................................................................៥៤

៣.២.២. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា ឆ្នាំ ២០១៨.........................................................៥៤

**៣.៣. ក្របខណ្ឌតាមដាន និងវាយតម្លៃ**.........................................................................................៥៥

**៣.៤. ការបែងចែកភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការតាមដាន និងវាយតម្លៃ**....................៥៥

៣.៤.១. របាយកាណ៍ស្តីលទ្ធផលតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ..................................៥៦

**សេចក្តីសន្និដ្ឋាន**...........................................................................................................................៥៧

**អនុសាសន៍**...................................................................................................................................៥៨

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលបានឆ្លងកាត់សង្គ្រាមស៊ីវិលច្រើនដោយសារតែការឆ្លងកាត់សង្គ្រាមដែលបានអូសបន្លាប្រមាណបីទសវត្សរ៍ មិនត្រឹមតែបង្អាក់ការអភិវឌ្ឍននៅកម្ពុជាលើគ្រប់វិស័យប៉ុណ្ណោះទេប៉ុន្តែថែមទាំងបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ ប្រព័ន្ធនយោបាយ រដ្ឋបាល សង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី និងទំនាមទម្លាប់ ជាពិសេស នៅក្នុងប្រទេសកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ បន្ទាប់ពីប្រទេសកម្ពុជាបានចុះព្រមព្រៀងទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រួមទាំងផ្អែកលើគំនិតផ្តួចផ្តើមក្នុងការសម្របសម្រួលខាងគោលនយោបាយ ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលបានរៀបចំក្របខណ្ឌគោលនយោបាយសម្រាប់បោះឆ្នោតនៅថ្នាក់ស្រុក ខណ្ឌ និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវរៀបចំឡើងដោយនាឆ្នាំ១៩៩៩ និងបានឈានទៅដល់ច្បាប់ស្តីពីការការគ្រប់គ្រងរដ្ឋបាល ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋ ទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។ សមិទ្ធផលកំណែទម្រង់ដែលបានសម្រេចនៅថ្នាក់ស្រុក ខណ្ឌ បានជំរុញ និង លើកទឹកចិត្តដល់រាជរដ្ឋាភិបាល ដើម្បីពង្រីកដំណើរការកំណែទម្រង់នេះរហូតដល់ថ្នាក់ក្រោមជាតិ តាមរយៈការដាក់ចេញក្របខណ្ឌយុទ្ធសាស្ត្រ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥។ ផ្អែកលើតម្រូវការកំណែទម្រង់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មដោយបានរៀបចំដែនដីរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។ រាជធានីភ្នំពេញចែកជាខណ្ឌ ខណ្ឌចែកជា សង្កាត់ ខេត្តចែកជា ក្រុង និងស្រុក ក្រុងចែកជា សង្កាត់ ស្រុកចែកជា ឃុំនិងសង្កាត់ ប៉ុន្តែសង្កាត់ក្នុងស្រុកមិនទាន់មានឡើយ។

ក្នុងនោះរាជរដ្ឋាភិបាលបានដាក់ចេញនូវនយោបាយវិមជ្ឈការថ្នាក់ស្រុក ខណ្ឌ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងទិសដៅអាទិភាពធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ។ ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ រដ្ឋបាលស្រុក ខណ្ឌជាមណ្ឌលរដ្ឋបាលអនុវត្តន៍នយោបាយវិមជ្ឈការផង និងវិសហមជ្ឈការផង។ ក្នុងដំណើរការនេះ រាជរដ្ឋាភិបាលបានចាត់ទុកដំណើរការ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្វិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋ។ ដើម្បីពង្រឹងនិងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងជំរុញការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។ ជាពិសេសបានទទួលនូវផលប្រយោជន៍បីធំៗរួមមានផ្តល់លទ្ធភាពប្រជាពលរដ្ឋក្នុងការចូលរួមធ្វើសេចក្តីសម្រេច ប្រសិទ្ធភាពខ្ពស់នៃការផ្តល់សេវាធារណៈនិងការកៀរគរធនធាននៅមូលដ្ឋាន។

ក្នុងន័យនេះដែល សិទ្ធិអំណាចដែលទទួលយកដោយក្រុមតំណាងប្រជាពលរដ្ឋមូលដ្ឋាន (ក្រុមប្រឹក្សាស្រុក ខណ្ឌ) ជាអ្នកគ្រប់គ្រងរដ្ឋបាលស្រុក ខណ្ឌដែលធ្វើសកម្មភាពបម្រើផលប្រយោជន៍ជូនសាធារណៈក្នុងកិច្ចការអភិវឌ្ឍផលប្រយោជន៍របស់ខ្លួនក្នុងមូលដ្ឋានស្រុក ខណ្ឌ។

ដោយសារ ការសង្កេតឃើញនូវទិដ្ឋភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈបែបនេះហើយដែលជាចំណាប់អារម្មណ៍ របស់ក្រុមយើងខ្ញុំទាំងពីរនាក់បានឈានដល់ការសម្រេចចិត្តជ្រើសរើសយកប្រធានបទគឺ **(ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ នៅខេត្តកំពង់ចាមបច្ចុប្បន្ន)** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ និងដើម្បីស្វែងយល់កាន់តែច្បាស់លាស់អំពីការអនុវត្តនយោបាយវិមជ្ឈការនៅថ្នាក់រដ្ឋបាលស្រុកខណ្ឌ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ២. ចំណោទបញ្ហា

យោងតាមលំនាំបញ្ហា បានជំរុញឱ្យក្រុមប្រឹក្សាស្រុកបាធាយ ខេត្តកំពង់ចាម មានការទទួលខុសត្រូវលើការគ្រប់គ្រងកិច្ចការរដ្ឋបាល ស្រុកបាធាយ ខេត្តកំពង់ចាម ការផ្តល់សេវាសាធារណៈ ការពារផលប្រយោជន៍ការរស់នៅរបស់ប្រជាពលរដ្ឋនិងដោះស្រាយបញ្ហាប្រឈមក្នុងដែនសមត្ថកិច្ចតាំងនាមជាអ្នកតំណាង និងអ្នកដឹកនាំការពារប្រជាពលរដ្ឋក្នុងគ្រាមានទុកលំបាក។ ដូចនេះចំណុចសំខាន់នៃការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពីការគ្រប់គ្រងរដ្ឋបាលរដ្ឋបាលស្រុកបាធាយតាមបែបវិមជ្ឈការផ្តោចសំខាន់ៗលើបញ្ហាដូចខាងក្រោម៖

- ហេតុអ្វីបានជារដ្ឋបាលថ្នាក់ស្រុកបាធាយ ត្រូវគ្រប់គ្រងតាមបែបវិមជ្ឈការ?
- តើរដ្ឋបាលស្រុកបាធាយបានអនុវត្តន៍តាមនយោបាយវិមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានដល់កម្រិតណា? មានតម្លាភាព គណនេយ្យភាព គុណភាព និងប្រសិទ្ធភាពដែរឬទេ?
- តើការគ្រប់គ្រងនិងបំពេញការងាររបស់រដ្ឋបាលស្រុកបាធាយមានមានដំណើរការយ៉ាងណា?
- តើមានបញ្ហាប្រឈមនិងដំណោះស្រាយអ្វីខ្លះក្នុងការអនុវត្តគ្រប់គ្រងការងាររបស់រដ្ឋបាលដើម្បីដោះស្រាយនិងកែលម្អបញ្ហាទាំងនោះឱ្យបានល្អប្រសើរ?
- តើលទ្ធផលនៃការអនុវត្តកន្លងមកនៅសាលាស្រុកបាធាយ ទទួលបានលទ្ធផលយ៉ាងណា?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ហេតុអ្វីបានជាក្រុមយើងខ្ញុំជ្រើសរើសយកប្រធានបទ(ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយខេត្តកំពង់ចាមបច្ចុប្បន្ន) មកសិក្សាស្រាវជ្រាវ?

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធាននេះគឺមែងតែងចង់ឱ្យនិស្សិតគ្រប់រូបនិងសាធារណៈជនមានគោលបំណងដូចខាងក្រោម៖

- ឱ្យសាធារណៈជន និងប្រជាពលរដ្ឋនៅក្នុងស្រុកបានយល់ដឹងច្បាស់បន្ថែមអំពីការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ និងតួនាទី ភារកិច្ចការងាររបស់អាជ្ញាធររដ្ឋបាលស្រុកបាធាយ
- សិក្សាស្វែងយល់អំពីដំណើរការទូទៅនៃការគ្រប់គ្រងរដ្ឋបាល និងអនុវត្តកិច្ចការរដ្ឋបាលស្រុកបាធាយនាពេលបច្ចុប្បន្ន
- ស្វែងយល់បន្ថែមពីការគ្រប់គ្រង និងរចនាសម្ព័ន្ធ តួនាទី មុខងារ អំណាច របស់រដ្ឋបាលស្រុកបាធាយ
- សិក្សាអំពីរបៀបបម្រើសេវាសាធារណៈ នៃប្រព័ន្ធអភិបាលកិច្ចល្អរបស់ស្រុកបាធាយ
- សិក្សាលើបច្ចុប្បន្នភាពរដ្ឋបាល ការអភិវឌ្ឍនៃការគ្រប់គ្រង រៀបចំចាត់ចែងលើការងាររដ្ឋបាល
- រួមចំណែកក្នុងការកែលម្អនៅចំណុចខ្វះខាត ពាក់ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ និងជំរុញកិច្ចអភិវឌ្ឍន៍សង្គមប្រកបដោយតម្លាភាព និងសុវត្ថិភាព
- សិក្សាស្វែងយល់ពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន បញ្ហាប្រឈមត្រូវដោះស្រាយតាមនីតិវិធីនៃការគ្រប់គ្រងរដ្ឋបាលតាមវិមជ្ឈការ។

## ៤. ទំហំនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវមានដែនកំណត់អំពីវិសាលភាពគ្របដណ្តប់ទៅតាមកម្រិត និងរយៈពេលស្រាវជ្រាវប្រធានបទ (**ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ នៅខេត្តកំពង់ចាមបច្ចុប្បន្ន**) ការស្រាវជ្រាវនេះផ្តោតទៅលើការគ្រប់គ្រងរដ្ឋបាល ស្រុកបាធាយ ខេត្តកំពង់ចាម តាមបែបវិមជ្ឈការ យើងខ្ញុំសូមធ្វើការបកស្រាយលើទៅ ចំណុចដែលទាក់ទងជាមួយដំណើរការគ្រប់គ្រងរដ្ឋបាល សមិទ្ធផលសម្រេចបាននូវបញ្ហាប្រឈម ទិសដៅអនាគត និងដំណោះស្រាយលើបញ្ហាផ្សេងៗរបស់រដ្ឋបាលស្រុកបាធាយ។

## ៥. សារៈសំខាននៃការសិក្សាស្រាវជ្រាវ

ជាទូទៅការសិក្សាស្រាវជ្រាវតែងតែមានគុណតម្លៃដល់អ្នកអាន និងអ្នកសិក្សាគ្រប់រូបលើប្រធានបទឬមុខជំនាញដែលខ្លួនជ្រើសរើសមានសារៈសំខាន់ ក្នុងការសិក្សាស្រាវជ្រាវបានយល់ដឹង និងចង់ចាំយ៉ាងច្បាស់ កាន់តែលម្អិតលើប្រធានបទ។បន្ទាប់មកវាបានផ្តល់សារៈប្រយោជន៍ជាច្រើនទៀតដល់អ្នកអាន និងអ្នកសិក្សាជំនាន់ក្រោយដែលបានសិក្សាអាននូវស្នាដៃស្រាវជ្រាវនេះ។សារៈប្រយោជន៍ដោយផ្អែកលើចំណុចមួយចំនួនដូចខាងក្រោម៖

- សារៈប្រយោជន៍សម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងរដ្ឋបាលស្រុកបាធាយ
  - យល់ដឹងពីរបៀបរៀបចំការងាររដ្ឋបាលក្នុងស្រុកបាធាយ
  - ដឹងពីគម្រោងការអភិវឌ្ឍ របស់រដ្ឋបាលស្រុកបាធាយ
  - ដឹងបន្ថែមពីការគ្រប់គ្រង និងរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់រដ្ឋបាលស្រុកបាធាយ
  - យកចិត្តទុកដាក់របស់រដ្ឋបាលស្រុកបាធាយ ចំពោះប្រជាពលរដ្ឋមូលដ្ឋាន។

❖ ប្រយោជន៍សម្រាប់និស្សិត

- ស្របតាមទិសដៅរបស់សាលកវិទ្យាល័យ ក្នុងការបញ្ចប់ថ្នាក់បរិញ្ញប័ត្របានដោយជោគជ័យ
- ស្វែងយល់អំពីដំណើរការ យន្តការនៃការគ្រប់គ្រងរដ្ឋបាល និងអនុវត្តកិច្ចការរដ្ឋបាលស្រុកបាធាយ នាពេលបច្ចុប្បន្ន
- យល់ដឹងពីយុទ្ធសាស្ត្រក្របខណ្ឌច្បាប់និងគោលនយោបាយក្នុងការបម្រើសេវាសាធារណៈ និងអភិបាលកិច្ចល្អជូនប្រជាពលរដ្ឋ។

❖ ប្រយោជន៍សម្រាប់សាកលវិទ្យាល័យ និងសាធារណៈជន និងប្រទេសជាតិ

- សាកលវិទ្យាល័យទទួលបានឯកសាសម្រាប់តម្កល់ទុក
- និស្សិតអ្នកអាននិងសាធារណៈជនអាចស្វែងយល់បន្ថែមពីទ្រឹស្តីមួយចំនួនក្នុងការសិក្សាស្រាវជ្រាវ និងយល់ច្បាស់ពីការងាររដ្ឋបាលរបស់ស្រុក
- ស្រុកមានសណ្តាប់ធ្នាប់ល្អ និងមានសុវត្ថិភាព,ការអភិវឌ្ឍច្រើនដោយមកពីការខិតខំប្រឹងប្រែងរបស់រដ្ឋបាលស្រុកបាធាយ
- បង្ហាញពីភាពស្មោះរបស់ថ្នាក់ដឹកនាំ និងការចូលរួមមិនអាចខ្វះបានពីប្រជាពលរដ្ឋ នាំឱ្យស្រុកមានការរីកលូតលាស់លឿន ធ្វើឱ្យប្រទេសជាតិមានការរីកចម្រើន
- ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋបានល្អ មានតម្លាភាព សន្តិភាព តាំងនាមជាអ្នកដឹកនាំដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានកំណត់នូវការសិក្សាស្រាវជ្រាវនៅក្នុង (**ការគ្រប់គ្រង់រដ្ឋបាលស្រុកបាធាយ នៅខេត្តកំពង់ចាមបច្ចុប្បន្ន**) ដើម្បីធ្វើការប្រមូលទិន្នន័យសម្រាប់ផលិតចងក្រងជាសារណាមួយឱ្យមានខ្លឹមសារស៊ីជម្រៅ និងប្រធានបទ និងមានសកម្មភាពស្រាវជ្រាវដូចខាងក្រោម៖

- ប្រមូលលិខិតបទដ្ឋានគតិយុទ្ធនានាដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងផ្សេងៗ
- ការចុះស្រាវជ្រាវឯកសារនៅសាលាស្រុកបាធាយ
- ការប្រមូលព័ត៌មាននៅបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ការជួបសម្ភាសន៍ការណែនាំផ្ទាល់ពីសាស្ត្រាចារ្យដឹកនាំ
- ការប្រមូលទិន្នន័យនិងឯកសារជាច្រើនទៀតតាមរយៈប្រព័ន្ធអេឡិចត្រូនិច មានប្រព័ន្ធអ៊ីនធឺណេតនិងប្រព័ន្ធផ្សព្វផ្សាយនានាជាច្រើនទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវប្រធានបទ **(ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ នៅខេត្តកំពង់ចាមចប្ចុប្បន្ន)** ត្រូវបានចងក្រងចែកចេញជាតាមប្លង់ដូចខាងក្រោមនេះ ៖

- **សេចក្តីថ្លែងអំណរគុណ៖** បរិយាយអំពីការគោរពការដឹងគុណ និងការថ្លែងអំណរគុណចំពោះលោកអ្នកមានគុណទាំងពីរ លោកសាស្ត្រាចារ្យ ឯកឧត្តមសាលកវិទ្យាធិការ លោកសាស្ត្រាចារ្យណែនាំ លោកចៅហ្វាយស្រុក មិត្តភក្តិរួមជំនាន់ទាំងអស់ដែលបានរួមចំណែកយ៉ាងធំធេងនិងជួយឱ្យយើងទាំងពីរនាក់បានបញ្ចប់ការសិក្សារដោយជោគជ័យ។
- **អារម្ភកថា៖** បរិយាយអំពីអារម្មណ៍និងការយល់ឃើញចំពោះប្រធានបទដែលពួកយើងទាំងពីរបានខិតខំស្រាវជ្រាវ និងស្វែងរកឯកសារមួយចំនួនមកបន្ថែមទៀត។
- **សេចក្តីផ្តើម៖** និយាយអំពីបញ្ហាដែលបានបង្ហាញ និងពណ៌នាពីចំណុចដំបូងបំផុតនៃប្រធានបទអំពីការកកើតឡើងដំបូងនៃការរៀបចំគោលនយោបាយបោះឆ្នោតស្រុកខណ្ឌ ការធ្វើវិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។
- **ជំពូកទី១ រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ៖** ជំពូកនេះបង្ហាញពីទ្រឹស្តីមួយចំនួនដែលពាក់ព័ន្ធនិងប្រធានបទ ដែលដូចជា ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលការណ៍នៃអភិបាលកិច្ចល្អ។
- **ជំពូកទី២ ដំណើរការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ៖** ជំពូកនេះបង្ហាញអំពី ស្ថានភាពទូទៅ ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលស្រុក ខណ្ឌ តួនាទី មុខងារនិងការទទួលខុសត្រូវរដ្ឋបាលស្រុកបាធាយ ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល។
- **ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយ៖** ជំពូកនេះបានលើកឡើងអំពី សមិទ្ធផលដែលរដ្ឋបាលស្រុកបាធាយសម្រេចបាន បញ្ហាប្រឈម និងដំណោះស្រាយរួមទាំងលិខិតបទដ្ឋានគតិយុត្ត និងការដាក់ចេញសេវារដ្ឋបាលសាធារណៈ។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** ផ្នែកនេះជាចំណុចចុងក្រោយនៃសារណានេះ ដោយសង្ខេបនូវរាល់លទ្ធផលទាំងអស់ ដែលទទួលបានពីការស្រាវស្រាវ និងបង្ហាញពីអនុសាសន៍មួយចំនួន។

# ជំពូកទី១

# រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ

# ជំពូកទី១
# រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ

## ១.១. ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ។ ដោយសារវិមជ្ឈការជាធាតុផ្សំសំខាន់ក្នុងការអនុវត្ត នៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ ប្រព័ន្ធវិមជ្ឈការកម្ពុជាមានគោលបំណងចម្បងបីយ៉ាងគឺ(១)ជំរុញឱ្យមានដំណើរការលទ្ធិប្រជាធិបតេយ្យនិងការគ្រប់គ្រងបែបយ៉ាងនៃអភិបាលកិច្ចល្អនៅមូលដ្ឋានជំរុញគុណភាពក្នុងការរស់នៅឱ្យកាន់តែល្អប្រសើររបស់ប្រជាពលរដ្ឋ។ (២)ផ្តល់ជូនឱកាសលទ្ធិភាពកាន់តែច្រើនឡើងដល់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តរៀបចំការអភិវឌ្ឍនៅមូលដ្ឋាន និង(៣)ធានាការអភិវឌ្ឍប្រកបដោយចីរភាពរួមទាំងការបែងចែកនូវសេវាកម្មជាមូលដ្ឋានផ្សេងៗ។[1]

រាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថា វិមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជារាស្ត្រ លើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជារាស្ត្រ និងលើកកម្ពស់ការផ្តល់នូវសេវាកម្មចាំបាច់ដល់មូលដ្ឋានសមស្របទៅតាមតំរូវការជាក់ស្តែងរបស់ខ្លួន។ ការរៀបចំ ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានដែលធានាឱ្យមានការចូលរួមប្រាស្រ័យពីប្រជាពលរដ្ឋគឺជាវិធីសាស្ត្រគ្រប់គ្រង តម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលខ្ពស់។ វិមជ្ឈការ គឺជាមធ្យោបាយដ៏ល្អប្រសើរបំផុតសម្រាប់លើកកម្ពស់អភិបាលកិច្ចល្អ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រសំដៅអភិវឌ្ឍប្រទេសទាំងមូល។ ដូច្នេះ ការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការជ្រើសរើសក្រុមប្រឹក្សាស្រុកឱ្យអនុវត្តន៍នូវការគ្រប់គ្រងតាមនយោបាយវិមជ្ឈការគឺជាការថ្លឹងថ្លែងពិចារណាយ៉ាងហ្មត់ចត់ ដោយមានហេតុផលជាក់ស្តែងនិងសមស្របបំផុតសម្រាប់បរិបទនៃប្រទេសកម្ពុជា។ ទន្ទឹមហេតុផលនេះរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ស្រុក ខណ្ឌ ដែលបានអនុម័តដោយរដ្ឋសភាកម្ពុជា ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការចាប់ផ្តើមអនុវត្តន៍នូវគោលនយោបាយវិមជ្ឈការនៅកម្ពុជា។

### ១.១.១. និយមន័យវិមជ្ឈការ

**វិមជ្ឈការ** គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារសិទ្ធិអំណាចនិងធនធានដើម្បីឆ្លើយតបទៅ និងសេចក្តីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះ។ ក្នុងន័យនេះ រាល់កិច្ចការនានាដែលបានធ្វើវិមជ្ឈការទៅឱ្យក្រុមប្រឹក្សាក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញក្នុងការគ្រប់គ្រងនិងចាត់ចែងកិច្ចការទាំងនោះ នៅក្នុងមូលដ្ឋានរបស់ខ្លួនទន្ទឹមនេះក្រុមប្រឹក្សាក៏ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តកិច្ចការទាំងនោះផងដែរ។

[1] ដកស្រង់ចេញពីសៀវភៅ វិមជ្ឈការ និងវិសហមជ្ឈការ , និពន្ធដោយ សាស្ត្រាចារ្យ កៅ មុយថង ឆ្នាំ២០០៧ ទំព័រទី៣

វាជាដំណើរមួយដែលសិទ្ធិអំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈ ត្រូវបានផ្ទេរពីរដ្ឋបាលកណ្តាលឱ្យទៅរដ្ឋបាលថ្នាក់មូលដ្ឋាន ដែលមានគោលបំណងទំនាក់ទំនងយ៉ាងជិតស្និតទៅនិងគោលគំនិតស្តីពីការបង្ហាញនូវការផ្ទេរអំណាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមលក្ខណៈដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលយកបានសមស្របទៅសមត្ថភាព ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

### ១.១.២. មុខងារវិមជ្ឈការ

វិមជ្ឈការមានមុខងារពីរខុសគ្នាគឺ៖

- **មុខងារនៃចម្រាញរូបកម្មនៃអំណាចរបស់រដ្ឋ៖** ពោលគឺនៅពេលធ្វើវិមជ្ឈការអំណាចរបស់រដ្ឋបង្ហាញឱ្យនូវការឃើញសេរីភាវូបនីយកម្ម និងរបបមួយមានលក្ខណៈប្រជាធិបតេយ្យ។ ហេតុនេះហើយនយោបាយក្នុងការធ្វើវិមជ្ឈការរបស់រដ្ឋ គឺនយោបាយមួយចំនេញខាងស្មារតី ឬចិត្តសាស្ត្រ និយាយរួមអំណាចកណ្តាលត្រូវបានគោរពដោយប្រជាពលរដ្ឋ។
- **មុខងារនៃការបំពេញចិត្តទាមទារចេញមកពីកម្លាំងនយោបាយនិងសង្គម៖**គឺជាអ្វីដែលមិនត្រូវពិនិត្យដោយឧបករណ៍រដ្ឋ និងជាកម្លាំងដែលទាមទារសេរីភាពជាសមូហភាពមួយផ្នែក។

### ១.១.៣. លក្ខណៈពិសេសនៃវិមជ្ឈការ

បច្ចេកទេសនៃការគ្រប់គ្រងតាមនយោបាយវិមជ្ឈការមានលក្ខណៈពិសេសចំនួន បីគឺ៖

- **បុគ្គលភាពគតិយុត្ត៖** សំដៅដល់ប្រព័ន្ធវិមជ្ឈការដែលមានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ។ ប្រព័ន្ធនេះជាប្រធាននៃនីតិខុសរដ្ឋ។ ប្រព័ន្ធទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចផ្ទាល់ខ្លួន មានគោលដៅ សិទ្ធិអំណាច និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន (ថវិកា សម្ភារៈ និងធនធានមនុស្ស)។
- **សមត្ថកិច្ចផ្ទាល់៖** សំដៅដល់ប្រព័ន្ធវិមជ្ឈការខុសពីសមត្ថកិច្ចរដ្ឋ។ ពោលគឺមានលក្ខណៈគតិយុត្តពីរគឺ៖ (១)មិនមែនជាសមត្ថកិច្ចគោលការណ៍ទេ ប៉ុន្តែជាសមត្ថកិច្ចដែលកំណត់ច្បាប់ និង(២)នៅពេលរដ្ឋបានកំណត់ភារកិច្ចឱ្យហើយរដ្ឋមិនអាចចូលធ្វើអន្តរាគមន៍បានឡើយ។
- **ការប្រើប្រាស់សមត្ថកិច្ចស្វយ័ត៖** មានន័យថាគ្មានរណបឋានុក្រមទេ រវាងរដ្ឋ និងប្រព័ន្ធវិមជ្ឈការគ្មានអំណាចបង្គាប់បញ្ជាទេ។ ប៉ុន្តែការត្រួតពិនិត្យរបស់អំណាចកណ្តាលនៅតែមាននូវឡើយព្រោះរដ្ឋនៅតែជារដ្ឋទោលដដែល ហើយស្វ័យភាពមិនមែនឯករាជ្យភាពទេ។ ការត្រួតពិនិត្យនេះ ត្រូវធ្វើឡើងតាមរបៀបពីរយ៉ាងដែលអង្គការត្រួតពិនិត្យអាចអង្គការតុលាការ ឬអាជ្ញាធររដ្ឋបាល។

### ១.១.៤. ទម្រង់ផ្សេងៗនៃវិមជ្ឈការ

ទម្រង់ផ្សេងៗនៃវិមជ្ឈការដែលមានកំណត់ជាច្រើនប្រភេទទៅតាមការបោះពុម្ពផ្សាយរបស់បុគ្គលល្បីៗនិងស្ថាប័នផ្សេងៗលើសកលលោកក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ។ទម្រង់វិមជ្ឈការនីមួយៗត្រូវផ្តោតសំខាន់ឈរលើគោលការណ៍អភិបាលកិច្ចល្អ និងអាស្រ័យតាមករណីពិសេសរបស់ប្រទេសនីមួយៗ។

**១.១.៤.១. វិមជ្ឈការរដ្ឋបាល**

វិមជ្ឈការរដ្ឋបាល ត្រូវបានគេចាត់ទុកថាមានការទាក់ទងនិងការអភិវឌ្ឍ គឺជាទម្រង់ទូទៅ និងត្រូវបានគេទទួលស្គាល់ថាទម្រង់វិមជ្ឈការ។ វិមជ្ឈការរដ្ឋបាល មានន័យថា ការផ្ទេរការទទួលខុសត្រូវក្នុងការរៀបចំផែនការការគ្រប់គ្រង និងបែងចែកប្រភពប្រាក់វិភាជន៍ពីរាជរដ្ឋាភិបាល និងភ្នាក់ងារផ្សេងៗរបស់ខ្លួនឱ្យមូលដ្ឋានអង្គភាពភ្នាក់ងាររាជរដ្ឋាភិបាលមូលដ្ឋាន ស្ថិតក្រោមបង្គាប់របស់រាជរដ្ឋាភិបាល ឬក្រុមហ៊ុនពាក់កណ្ដាលស្វយ័តអាជ្ញាធរមុខងារគេអាចហៅថាវិមជ្ឈការរដ្ឋបាលថាវិមជ្ឈការដែនដី។ វិមជ្ឈការដែនដីគឺត្រូវបានធ្វើឡើងទៅលើ នីតិបុគ្គលសាធារណៈដែនដី ដែលមានដែនដីវិសាលភាពទូលំទូលាយ ដូចជាខេត្តដែលហៅថា វិមជ្ឈការផ្ដល់ទៅឱ្យអភិបាលកិច្ច ឬសមូហភាពដែនដីវិញដែលមិនផ្ដោតលើអភិបាលកិច្ចឬសមូហភាពមូលដ្ឋានទេ។

នីតិបុគ្គលសាធារណៈដែនដី គឺមានក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោតហើយក្រុមប្រឹក្សានេះជាអ្នកបោះឆ្នោតជ្រើសរើសតាំងនាយប្រតិបត្តិ ដែលជាទូទៅមានអង្គទាំងពីរនេះ មានភារកិច្ច តួនាទីដោយឡែកពីគ្នា គឺក្រុមប្រឹក្សាមានតួនាទីជាអ្នកចេញសេចក្ដីសំរេចនានា ហើយនាយប្រតិបត្តិជាអ្នកអនុវត្តន៍សេចក្ដីសំរេច។

**១.១.៤.២. វិមជ្ឈការបច្ចេកទេស**

វិមជ្ឈការអំពីមុខងារដែលសិទ្ធិអំណាចមានពីរប្រភេទ គឺវិមជ្ឈការបច្ចេកទេស និងវិមជ្ឈការសេវាកម្មតម្រូវឱ្យមានការធ្វើវិមជ្ឈការនៅថ្នាក់រដ្ឋបាល។ វិមជ្ឈការបច្ចេកទេសជារបៀបគ្រប់គ្រងសេវាកម្មសាធារណៈដោយមានការទទួលខុសត្រូវអំពីសិទ្ធិអំណាចដឹកនាំគ្រប់គ្រងបច្ចេកទេសណាមួយឱ្យទៅអាជ្ញាធរមួយគ្រប់គ្រងតាម នៃច្បាប់ក្នុងគោលបំណងបម្រើផលប្រយោជន៍ទូទៅឱ្យមានប្រសិទ្ធិភាព។ ក្នុងបរិបទប្រទេសកម្ពុជា វិមជ្ឈការបច្ចេកទេសបានរៀបចំរួចរាល់ហើយ ពោលគឺដែលបានប្រគល់សិទ្ធិ ឱ្យគ្រប់គ្រងតាមបែបវិមជ្ឈការបច្ចេកទេសមានដូចជា អាជ្ញាធរកំចាត់មីន អាជ្ញាធរអប្សរា អាជ្ញាធរអគ្គសនេកម្មរដ្ឋករទឹក។ល។

**១.១.៤.៣. វិមជ្ឈការហិរញ្ញវត្ថុ និងសារពើពន្ធ**

ការស្ថាបនានូវប្រសិទ្ធិភាព តម្លាភាព គណនេយ្យភាព ការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃព្រះរាជាណាចក្រកម្ពុជាដើម្បីធ្វើការសម្រេចចិត្តប្រើប្រាស់ធនធានផ្សេងៗ។

ការទទួលខុសត្រូវខាងសារពើពន្ធ គឺជាធាតុផ្សំយ៉ាងសំខាន់នៃវិមជ្ឈការ ព្រោះថារដ្ឋបាលមូលដ្ឋានត្រូវមានប្រាក់ចំណូលគ្រប់គ្រាន់ (ប្រមូលនៅមូលដ្ឋាន និងបញ្ជូនពីថ្នាក់ជាតិ) ដើម្បីធ្វើការសម្រេចក្នុងការចំណាយ។ វិមជ្ឈការសារពើពន្ធមានទម្រង់ជាច្រើនដែលសរុបជារួមមកមានដូចជាខាងក្រោម៖

- ហិរញ្ញប្បទានផ្ទាល់ខ្លួន ឬការទូទាត់ចំណាយយកតាមថ្លៃពីអ្នកប្រើប្រាស់
- ការពង្រីកចំណូលនៅមូលដ្ឋានតាមរយៈពន្ធអាករ និងការយកថ្លៃដោយប្រយោល
- ការផ្ទេរហិរញ្ញប្បទានដែលមានលក្ខណៈអន្តររដ្ឋបាល
- ការផ្ដល់អំណាចក្នុងការខ្ចីហិរញ្ញប្បទានដើម្បីបម្រើផលប្រយោជន៍នៅមូលដ្ឋាន។

**១.១.៤.៤. វិមជ្ឈការនយោបាយ និងប្រជាធិបតេយ្យ**

វិមជ្ឈការនយោបាយ គឺជាការផ្តល់ឱ្យប្រជាពលរដ្ឋទាំងឡាយធ្វើការបោះឆ្នោតជ្រើសតាំងជាតំណាងពួកគាត់នូវការ ផ្តល់សិទ្ធិអំណាចច្រើនជាងមុន ក្នុងការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ។ ទាំងនេះជាការគាំទ្រឱ្យមានការផ្តាច់ចេញនូវសិទ្ធិអំណាចប្រមូលផ្តុំនៅថ្នាក់កណ្តាល។ ធ្វើបែបនេះ ដើម្បីធានាបាននូវតុល្យភាព និងប្រព័ន្ធត្រួតពិនិត្យចម្រុះក្នុងការអនុវត្តនយោបាយ ដើម្បីមានការអភិវឌ្ឍ។វិមជ្ឈការប្រជាធិបតេយ្យ មានការពាក់ព័ន្ធទៅនិងការផ្ទេររដ្ឋបាលសារពើពន្ធអំណាចនយោបាយគឺដើម្បីឱ្យមានវិមជ្ឈការទទួលបានជោគជ័យវិមជ្ឈការប្រជាធិបតេយ្យជាការពង្រឹងយ៉ាងសំខាន់ក្នុងគោលការណ៍សម្របសម្រួលដំណើរការរៀបចំនិងមានការអនុវត្តផែនការនៅមូលដ្ឋានហើយក៏ជាវិធីសាស្ត្រមួយដើម្បីភ្ជាប់ទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិលនិងធ្វើឯកជនសាកលភាវូបនីយកម្មផងដែរ វិមជ្ឈការប្រជាធិបតេយ្យ អាចជាដំណើរការដែលឈានទៅរកការបង្កើតឱ្យមានប្រធិបតេយ្យនៅមូលដ្ឋានក្នុងកិច្ចការងារអភិវឌ្ឍមូលដ្ឋាននិងព្រមទាំងសង្គមជាតិ។

## ១.២. ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១.២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺត្រូវមានក្រុមប្រឹក្សារបស់ខ្លួនដែលបានបង្កើតឡើង ដោយការបោះឆ្នោត ហើយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានគ្រប់គ្រងដោយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។[2] សមាជិករបស់ក្រុមប្រឹក្សាត្រូវបានជ្រើសរើសដោយការបោះឆ្នោតជាអសកល មិនចំពោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។[3] ចំពោះក្រុមប្រឹក្សាមានអាណត្តិប្រាំឆ្នាំ (០៥)ឆ្នាំ ដោយត្រូវបានផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវធ្វើឡើងតែមួយថ្ងៃ គឺនៅថ្ងៃអាទិត្យ កាលបរិច្ឆេទជាក់ស្តែងនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាកំណត់ដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[4]

### ១.២.២. សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយផ្អែកលើកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រដូចខាងក្រោម៖

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃប្រាំពីរ(២៧)រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីដប់ប្រាំ(១៥)រូប ដល់ម្ភៃប្រាំពីរ(២៧)រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីដប់មួយ(១១)រូប ដល់ម្ភៃមួយ(២១)រូប
- ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីដប់មួយ(១១)រូប ដល់ម្ភៃមួយ(២១)រូប។[5]

---

[2] មាត្រា១ នៃច្បាប់ស្តីការបោះឆ្នោះជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

[3] មាត្រា៤ នៃច្បាប់ស្តីការបោះឆ្នោះជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

[4] មាត្រា៥ នៃច្បាប់ស្តីការបោះឆ្នោះជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

[5] មាត្រា១៨ ថ្មី នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ,២០០៨

## ១.៣. គោលការណ៍នៃអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើនអាស្រ័យនិងស្ថានភាពជាក់ស្តែង។ ជាសាមញ្ញ អភិបាលកិច្ចល្អមានន័យថា៖ គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន ឬអង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាន ការគ្រប់គ្រងរបស់រដ្ឋបាលដែនដីនោះ។

❖ **ការចូលរួម**

ការចូលរួមក្នុងបរិបទអភិបាលកិច្ចល្អ គឺសំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី (អាជ្ញាធរ ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងទៀត) ក្នុងដំណាក់ការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ។ ការចូលរួមនេះត្រូវបានចែកចេញជាពីប្រភេទគឺ ការចូលរួមដោយផ្ទាល់ និងការចូលរួមតាមរយៈតំណាង។

ការចូលរួមដោយផ្ទាល់ មានន័យថាគឺជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯងផ្ទាល់ នៅក្នុងដំណើរនៃការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តនោះ។

ការចូលរួមតាមរយៈអ្នកតំណាង មានន័យថាគឺ អ្នកតំណាងរបស់ប្រជាពលរដ្ឋចូលរួមនូវដំណើរការក្នុងការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ។ អ្នកតំណាង ត្រូវតែបំពេញតួនាទីជាអ្នកតំណាងឱ្យមានឆន្ទៈ និងផលប្រយោន៍ប្រជាពលរដ្ឋដែលខ្លួនតំណាងឱ្យ។

❖ **នីតិរដ្ឋ**

និតីរដ្ឋក្នុងន័យអភិបាលកិច្ចល្អ ទាមទារឱ្យមានឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈ ការពារសិទ្ធមនុស្ស ជាពិសេសក្រុមងាររងគ្រោះ ឬក្រុមភាគតិចហើយច្បាប់ទាំងនោះត្រូវបានអនុវត្តឡើងដោយមិនលំអៀង។ លើសពីនេះទៀត ត្រូវមានប្រព័ន្ធទទួលខុសត្រូវ មានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយ។

❖ **តម្លាភាព**

តម្លាភាពក្នុងន័យអភិបាលកិច្ចល្អគឺរាល់ការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចត្រូវធ្វើឡើង៖

- ➢ ដោយអនុលោមទៅតាមច្បាប់ និងបទដ្ឋាននានា
- ➢ ព័ត៌មានពាក់ព័ន្ធ និងការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចិត្ត
- ➢ ព័ត៌មានទាំងនោះត្រូវមានលក្ខណៈគ្រប់គ្រាន់និងងាយយល់។ [6]

[6] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រ ក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ទំព័រទី១៣

**ឧទាហរណ៍**:ក្រុមប្រឹក្សាខណ្ឌ ពេលធ្វើការសម្រេចចិត្តអំពីអ្វីមួយត្រូវធ្វើដោយបើកចំហរនិងផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធទៅនិងការសម្រេចចិត្តនោះ ទៅកាន់ប្រជាពលរដ្ឋក្នុងមូលដ្ឋានខណ្ឌរបស់ខ្លួនឱ្យបានទាន់ពេលវេលា និង ធានានូវភាពជាក់លាក់អំពីព័ត៌មាននោះ ដើម្បីបញ្ចៀស និង កាត់បន្ថយរាល់ការសង្ស័យ និង ការការប្រព្រឹត្តអំពើពុករលួយក្នុងការសម្រេចនោះ។

- **ការព្រមព្រៀងឯកភាពគ្នា**
  - ការព្រមព្រៀងឯកភាពគ្នាក្នុងន័យ អភិបាលកិច្ចល្អ គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នា នៅក្នុងសង្គមហើយឈានទៅរកការសម្រេចចិត្តដោយមានការព្រមព្រៀងឯកភាពគ្នានៅក្នុងសង្គម ហើយឈានទៅរកការសម្រេចចិត្តដោយមានការព្រមព្រៀងឯកភាពគ្នាលើជម្រើស និងវិធីសាស្ត្រដែលបម្រើផលប្រយោជន៍សាធារណៈ។[7]

គោលការណ៍ណែនាំសម្រាប់សម្រសសម្រួលឱ្យមានការព្រមព្រៀងឯកភាពគ្នា៖

**១. លក្ខខណ្ឌនៃការព្រមព្រៀងឯកភាពគ្នា**

លក្ខខណ្ឌនៃការព្រមព្រៀងឯកភាពគ្នារួមមានៈ

- ការព្រមព្រៀងគ្នាប្រកបដោយសុខដុមរមនា
- ការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធទាំងអស់
- ការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត
- ការយល់ដឹងអំពីគ្នាទៅវិញទៅមក រវាងក្រុមពាក់ព័ន្ធទាំងអស់។

**២. ដំណើរការនៃការព្រមព្រៀងឯកភាពគ្នា**

ការណែនាំ ដើម្បីធ្វើការសម្រុះសម្រួលឱ្យមានការព្រមព្រៀងឯកភាពគ្នា៖

- រៀបចំឱ្យមានការជួបជុំគ្នារវាងក្រុមពាក់ព័ន្ធទាំងអស់
- ស្វែងយល់គ្នាទៅវិញទៅមករវាងក្រុមអ្នកពាក់ព័ន្ធ និងបង្កើតការយោគយល់ឱ្យគ្នាទៅវិញទៅមក
- ពិភាក្សាជាមួយក្រុមព័ន្ធទាំងអស់អំពីផលប្រយោជន៍ និង បង្កើតជម្រើសនានា
- សម្រុះសម្រួលដើម្បីសម្រេចយកជម្រើសល្អមួយដែលបម្រើផលប្រយោជន៍រួមដោយមានការព្រមព្រៀងឯកភាពគ្នាប្រកបដោយសុខដុមរមនា។

[7] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រ ក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ទំព័រទី១៤

❖ **សមធម៌**

➢ សមធម៌ក្នុងន័យអភិបាលកិច្ចល្អមានន័យថា ក្រុម ឬ ជនគ្រប់រូបទាំងអស់ ជាពិសេស ក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះ មានឱកាសគ្រប់គ្រាន់ នៅក្នុងការចូលរួមបញ្ចេញយោបល់ លើកឡើងនូវតម្រូវការពិតអនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្របដើម្បីកែលម្អ លើសពីនេះទៅទៀតអាចឱ្យពួកគេមានអារម្មណ៍ថាពួកគេគឺជាសមាជិកពិតប្រាកដរបស់សង្គម និង មិនត្រូវបានសង្គមមានការបោះបង់ចោលនោះទេ។ សុខាមាលភាពរបស់មនុស្ស សំដៅជាពិសេសលើភាពសប្បាយរីករាយ សុវត្ថិភាព ភាពសុខស្រួល បញ្ញាសន្តិសុខ សុខភាព។[8]

❖ **ប្រសិទ្ធិភាព និងភាពស័ក្តិសិទ្ធិ**

➢ ប្រសិទ្ធិភាព និងភាពស័ក្តិសិទ្ធិក្នុងន័យអភិបាលកិច្ចល្អ មានន័យថាជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុង ការប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព និងសន្សំសម្ចៃខ្ពស់ ដើម្បីបង្កើតលទ្ធផលដែលមានគុណភាពខ្ពស់ បរិមាណច្រើនអាចបម្រើប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅតម្រូវការពិតរបស់សង្គម។

❖ **គណនេយ្យភាព**

➢ គណនេយ្យភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការ និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុ នូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត ទៅដល់មុខអ្នកពាក់ព័ន្ធទាំងអស់។[9]

<u>**ឧទាហរណ៍៖**</u> ស្មៀងឃុំ ទទួលធ្វើសំបុត្រអាពាពិហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងខ្មែរ មួយច្បាប់ចំនួន១៥.០០០រពីគ្រួសារមួយ និងធ្វើសំបុត្រអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងជនជាតិបរទេសមួយច្បាប់ចំនួន៣០.០០០រ ពីគ្រួសារមួយការបង់ថ្លៃសេវាជាក់លាក់មិនស្មើគ្នាឡើងនៃគ្រួសារទាំងពីរនោះ ហើយស្មៀងត្រូវបង្ហាញបំភ្លឺនៃនីតិក្នុងការបង់ថ្លៃសេវានេះ ទៅគ្រួសារទាំងពីរនោះឱ្យបានយល់ច្បាប់អំពីការខុសគ្នាក្នុងការបង់ថ្លៃសេវានេះ។

❖ **ការឆ្លើយតប**

➢ ការឆ្លើយតបក្នុងន័យអភិបាលកិច្ចល្អមានន័យថា គឺជាការព្យាយាមខិតខំប្រឹងប្រែងរបស់អង្គភាពនិងស្ថាប័នដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និងមិនរើសអើងនៅក្នុងក្របខ័ណ្ឌពេលវេលាមួយ ដ៏សមហេតុផល។[10]

---

[8] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រ ក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ទំព័រទី១៥

[9] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រ ក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ទំព័រទី១៧

[10] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រ ក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ទំព័រទី១៨

- ❖ ចក្ខុវិស័យជាយុទ្ធសាស្ត្រ
  - ➢ អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈទូលំទូលាយ និងសម្រាប់រយៈពេលវែងអំពីអភិបាលកិច្ចល្អនិងការអភិវឌ្ឍធនធានមនុស្សដោយយកចិត្តទុកដាក់ខ្ពស់អំពីតម្រូវការចាំបាច់នានាដែលត្រូវអភិវឌ្ឍន៍លើការងារ។ ជាងនេះទៀតអ្នកដឹកនាំទាំងអស់ត្រូវមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីទិដ្ឋភាពនានាផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម ដែលពាក់និងអភិបាលកិច្ចល្អ។[11]

[11] សៀវភៅ អភិបាលកិច្ចល្អ បោះពុម្ពលើកទី៤ ខែកុម្ភៈ ឆ្នាំ២០១៣

# ជំពូកទី២

# ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ

# ជំពូកទី២

# ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ

## ២.១. ស្ថានភាពព័ត៌មានទូទៅ

ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយបានអនុវត្តតាមបណ្តាគោលដៅ និងយុទ្ធសាស្ត្រអាទិភាព ដើម្បីកាត់បន្ថយភាពក្រីក្របង្កើនសុខុមាលភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ដោយមានការរួមចំណែកសំខាន់ពីបណ្តាលភ្នាក់ងារ អភិវឌ្ឍន៍, មន្ទីរវិស័យ, អង្គការជាតិ អន្តរជាតិ និងសប្បុរសជន។

### ២.១.១. ស្ថានភាពភូមិសាស្ត្រ

ស្រុកបាធាយជាស្រុកមួយក្នុងចំណោមស្រុក៩ និងក្រុង ១ នៃខេត្តកំពង់ចាម ហើយក៏ជាស្រុកមួយដែលទើបបំបែកចេញពីស្រុកជើងព្រៃនៅក្នុងឆ្នាំ១៩៨៧។ ស្រុកមានចម្ងាយផ្លូវប្រមាណ ៦៤គ.ម ពីទីរួមខេត្តកំពង់ចាម និងប្រមាណ ៦៥គ.ម ពីរាជធានីភ្នំពេញ។

- ស្រុកបាធាយមានព្រំប្រទល់ខាងកើតជាប់ស្រុកជើងព្រៃ និងស្រុកកងមាស
- ខាងលិចជាប់ និងស្រុកជលគីរី និងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
- ខាងជើងជាប់ និងស្រុកបារាយណ៍ ខេត្តកំពង់ធំ
- ខាងត្បូងជាប់ និងស្រុកមុខកំពូល និងស្រុកពញាឮ ខេត្តកណ្តាល។

ស្រុកបាធាយចែកជា**១២ឃុំ** រួមមាន៖ ឃុំបាធាយ,ឃុំច្បារអំពៅ,ឃុំជាលា,ឃុំជើងព្រៃ,ឃុំមេព្រីង,ឃុំផ្អាវ, ឃុំសំបួរ,ឃុំសណ្តែក,ឃុំតាំងក្រាំង,ឃុំតាំងក្រសាំង,ឃុំត្រប់ និងឃុំទំនប់សរុបស្មើនិង **៨០ភូមិ** ក្នុងនោះ ៤ឃុំ ស្ថិតនៅសងខាងផ្លូវជាតិលេខ 6A និង ១ ឃុំទៀត ស្ថិតនៅសងខាងផ្លូវជាតិលេខ ៦១ គឺឃុំសំបួរ។

ផ្ទៃដីរួមរបស់ស្រុកធាបាយ ផ្ទៃដីសរុប **៥៨៩.៩៥ គ.ម²** ចែកចេញជា ៖

- ផ្ទៃដីភូមិជាទីតាំងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋចនួន ៣២២ ហិកតា
- ផ្ទៃដីដាំដុះ **៣៦,៨៩០** ហិកតា
- ផ្ទៃដីព្រៃ ចំការចំនួន ៦៧ ហិកតា។

ប្រជាជនសរុបប្រមាណ **១២៨,២៦៨**នាក់ និងស្រីប្រមាណ **៦៥,៣៧៧**នាក់,ដង់ស៊ីតេប្រជាជន **២១៧ នាក់/គ.ម²**។ ប្រជាជនប្រមាណ ៦៩.៣% ជាកសិកររស់នៅពឹងផ្អែកលើវិស័យកសិកម្មដែលជាវិស័យចម្បង ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងស្រុកបាធាយ។

ក្រៅពីវិស័យកសិកម្មដែលជាស្នូល(**ជាចម្បង**)ប្រជាពលរដ្ឋដែលមានមុខរបរសេវាកម្មជាចម្បងប្រមាណ ៣០.៦% មុខរបរសិប្បកម្មជាចម្បង ០.២% និងមុខរបរមិនច្បាស់លាស់ (ចម្រុះ) ៦.២%។

## ២.២. ការរៀបចំរដ្ឋបាលស្រុក ខណ្ឌ

### ២.២.១. រចនាសម្ព័ន្ធការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ




### ២.២.២. ក្រុមប្រឹក្សា

ក្រុមប្រឹក្សាស្រុកដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ២.២.៣. សិទ្ធិអំណាចក្រុមប្រឹក្សាស្រុក

ក្រុមប្រឹក្សាស្រុកមានសិទ្ធិអំណាចពីរ គឺ៖

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ។

ក្រុមប្រឹក្សាស្រុកត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួនដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។ ប្រធានក្រុមប្រឹក្សាស្រុកក្នុងនាមក្រុមប្រឹក្សាស្រុករបស់ខ្លួនមានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រាទៅលើរដ្ឋបាលស្រុក៖

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាស្រុកបានអនុម័តរួច

- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្រុក
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាស្រុកបានអនុម័ត
- សំណើដកហូតអភិបាលស្រុកឬអភិបាលរងស្រុកចេញពីមុខតំណែងតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្រុក
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាស្រុក
- ប្រតិទិនកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាស្រុកសម្រាប់រយៈពេល១២ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាស្រុក
- កិច្ចការដ៏ទៃទៀតតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលស្រុកត្រូវជួយក្រុមប្រឹក្សាស្រុករបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះលើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទង និងសំណើដកហូតអភិបាលស្រុក ឬអភិបាលរងស្រុកឱ្យចេញពីមុខតំណែង។

### ២.២.៤. របៀបរបបការងាររបស់ក្រុមប្រឹក្សាស្រុក

ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវពិនិត្យពិចារណាលើចំនុចសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធនិងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

- ក្រុមប្រឹក្សាស្រុក ត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិតាមរយៈដីកា និងសេចក្តីសម្រេចខាងប្រតិបត្តិ។ រាល់សេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិត្រូវធ្វើឡើងក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុករបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនេះ ត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។
- ក្រុមប្រឹក្សាស្រុកអាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយអាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដើម្បីស្រាវជ្រាវ រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់គណៈអភិបាលស្រុកត្រូវដឹកនាំ នាយករដ្ឋបាលសាលាស្រុក និងការិយាល័យពាក់ព័ន្ធនៃសាលាស្រុក ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់បច្ចេកទេស ហើយនិងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ។
- ក្រុមប្រឹក្សាស្រុកត្រូវចាត់ឱ្យអភិបាលស្រុកចាត់ចែងផ្សព្វផ្សាយជាសាធារណៈ ជាបន្ទាន់នូវដីកាឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្រុកបានអនុម័តរួចលើកលែងតែមានការកំណត់ផ្សេងពីនេះព្រមទាំងចាត់ចែងការអនុវត្តឱ្យមានប្រសិទ្ធភាព។

- ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវចាត់ឱ្យគណៈអភិបាលស្រុកធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទ និងនីតិវិធីសមស្របដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យ និងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនោះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទនីតិវិធីដើម្បីដោះស្រាយ។
- ក្នុងករណីកិច្ចការណាមួយ ដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ ឬមិនស្របនិងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាស្រុកមិនអាចអនុវត្តបាន ក្រុមប្រឹក្សាស្រុកត្រូវចាត់ឱ្យគណៈអភិបាល ស្រុកធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ ដោយផ្អែកតាមយន្តការ គ.ជ.អ.ប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។
- ដើម្បីលើកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះប្រជាពលរដ្ឋរបស់ខ្លួន ក្នុងការប្រើប្រាស់នៃអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវរៀបចំឱ្យមានយន្តការពិគ្រោះ ពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក។

### ២.២.៥. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុកមានពីរប្រភេទ៖

- **កិច្ចប្រជុំសាមញ្ញ៖** ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ចំនួន១២ដងក្នុងមួយឆ្នាំ
- **ការប្រជុំវិសាមញ្ញ៖** ក្រុមប្រឹក្សអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបាន តាមតម្រូវការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ឬពិសេស។[12]

កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញអាចយកជាការបានលុះត្រាតែកិច្ចប្រជុំទាំងនេះប្រព្រឹត្តទៅឱ្យត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាស្រុក។ សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើង មិនស្របនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាស្រុក ឬរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានាដែលសេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។ រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍។

[12] សៀវភៅ សមត្ថ និងរបៀបរបបនៅរដ្ឋបាលថ្នាក់ក្រោមជាតិ , និពន្ធដោយ អនុបណ្ឌិត ហៀង សាង

គោលនយោបាយរបស់រដ្ឋបាលស្រុកនិងជាវិធានការបែបបទនីតិវិធីចាត់ចែងការងារតាមការចាំបាច់ដែលទាក់ទងទៅនិង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាស្រុក
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំផែនការអនុវត្តរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរួមទាំងសមាសភាពនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នាឬជាប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នាក្រសួង ស្ថាប័នឬមន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាលនិងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលស្រុក
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរួមទាំងការរៀបចំគណៈកម្មាធិការនៃការិយាល័យបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាស្រុកដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានា តាមតម្រូវការរបស់ក្រុមប្រឹក្សាស្រុក
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនរួមទាំងការពិគ្រោះយោបល់ជាមួយ ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងស្រុក និងការផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ស្រុក
- សមិទ្ធផល និងបញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ច របស់ក្រុមប្រឹក្សាស្រុក
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្ត។

## ២.៣. គណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំឱ្យមានគណៈអភិបាលដែលរួមមាន ប្រធានមួយរូបហៅថាអភិបាល និងអភិបាលរងមួយរូប។[13]

សមាជិកគណៈអភិបាលកំណត់រួមមានដូចជា៖

- គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប
- គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប

[13] មាត្រា១៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , ២០០៨

- គណៈអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប។[14]

ចំនួនជាក់ស្តែងនៃគណៈអភិបាលខេត្តក្រុងស្រុកខណ្ឌត្រូវបានកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលរាជធានីអភិបាលខេត្តត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយកមន្ត្រី និងតាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ អភិបាល អភិបាលរងមានអាណត្តិមិនលើសពីបួន(០៤)ឆ្នាំឡើយ តែអាចតែងតាំងបាន ចំនួនបួន(០៤)ឆ្នាំទៀតសម្រាប់ អាណត្តិទី២របស់ខ្លួន នៅក្នុងដែនសមត្ថកិច្ចដដែល។ អភិបាល អភិបាលរងមិនមែនជាសមាជិករបស់ក្រុមប្រឹក្សាទេ។

### ២.៣.១. តួនាទី និងភារកិច្ចរបស់គណៈអភិបាលស្រុក

គណៈអភិបាលស្រុកមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- គណៈអភិបាលស្រុកត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាស្រុក អំពីកិច្ចការនានាដែលពាក់ព័ន្ធនិងអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក។

ដើម្បីក្រុមប្រឹក្សាស្រុកធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនិងៈ

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាស្រុក និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ស្រុក
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា

[14] មាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , ២០០៨

- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុរបស់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាស្រុកគណៈអភិបាលស្រុកនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាស្រុក។

ចំពោះពិនិត្យ និងអនុម័ត មិនឱ្យលើសពី៤៥ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនិងៈ

- ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយ ក្រុមប្រឹក្សាស្រុក និងសកម្មភាពលទ្ធផលនៃការអនុវត្ត
- របាយការណ៍ហិរញ្ញវត្ថុ
- ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលស្រុកនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក
- វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។
- កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ
- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការវាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក និងតម្រូវការគាំទ្រចំពោះឃុំ សង្កាត់
- កិច្ចសហការ និងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុករបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា
- នៅពេលបានទទួលរាយការណ៍ឬព័ត៌មានអំពីការរំលោភអំណាច នៃគណៈអភិបាលស្រុកហើយត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថាមានការរំលោភអំណាចពិតប្រាកដមែនគណៈអភិបាលស្រុក ត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សាស្រុក និងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលស្រុកមានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងស្រុក។ ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលអភិបាលស្រុកត្រូវៈ

- ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយរបស់សាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងស្រុកអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុក។

- ធ្វើជាគណៈប្រធានបញ្ជាការឯកភាពស្រុក ក្នុងការដឹកនាំសម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និងសង្កាត់នៅក្នុងស្រុក ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយជាសាធារណៈនៅក្នុងស្រុក។
- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅស្រុកឱ្យអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់គោលនយោបាយជាតិនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនិងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ។
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។
- ពិនិត្យ វាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុប្រធានការិយាល័យអង្គភាព ស្ថាប័ននានាដែលប្រចាំនៅស្រុក។
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាស្រុកជាមុន ក្នុងការផ្តល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំនៅស្រុករបស់ខ្លួន។
- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវ នៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តកម្មបាន។[15]

### ២.៣.២. របៀបរបបការងាររបស់គណៈអភិបាលស្រុក

ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន គណៈអភិបាលស្រុក អភិបាលស្រុក អភិបាលរងស្រុក ត្រូវពិនិត្យពិចារណាលើចំណុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនិងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

- ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន អភិបាលស្រុកត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលច្បាប់លិខិតបទដ្ឋានគតិយុត្តនានានិងការណែនាំរបស់រាជរដ្ឋាភិបាលក្រសួងស្ថាប័ន និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងស្ថាប័ននានាស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។
- ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន និងការងារដ៏ទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលស្រុកត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលស្រុករបស់ខ្លួន។

[15] សៀវភៅ សមត្ថ និងរបៀបរបបនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, និពន្ធដោយ អនុបណ្ឌិត ហៀង សាង និង អនុបណ្ឌិត ម៉េង ឆុង ឆ្នាំ២០១១

ដោយឈរលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងការសម្រេច និងគោលការណ៍នាំពីក្រុមប្រឹក្សាស្រុករបស់ខ្លួន។

- អភិបាលស្រុកត្រូវទទួលខុសត្រូវចំពោះ មុខក្រុមប្រឹក្សាស្រុកអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលស្រុករបស់ខ្លួន។
- ដើម្បីធានាឱ្យបានគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលស្រុកត្រូវជួបប្រជុំប្រចាំនៃអឌ្ឍមាស ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។
- គណៈអភិបាលស្រុកត្រូវប្រជុំពិភាក្សា ដើម្បីបែងចែកភារកិច្ចដល់អភិបាលស្រុក និងអភិបាលស្រុករងស្រុក ហើយសុំការសម្រេចពីក្រុមប្រឹក្សាស្រុករបស់ខ្លួន។[16]
- អភិបាលស្រុក ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ និងដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សាស្រុករបស់ខ្លួនលើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាស្រុកចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាស្រុករបស់ខ្លួន។អភិបាលស្រុកអាចប្រគល់សិទ្ធិដល់អភិបាលរងស្រុក ក្នុងការចុះហត្ថលេខាលើឯកសារលិខិតស្នាមរដ្ឋបាលជាចាំបាច់មួយចំនួននៅក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងស្រុកនីមួយៗ។ប៉ុន្តែអភិបាលស្រុកត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងស្រុក។
- អភិបាលស្រុកមានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងស្រុកណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់និងមិនស្របតាមបែបបទនីតិវិធី។
- ក្នុងករណីអភិបាលស្រុកអនុវត្តមាន អភិបាលស្រុកត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងស្រុកមួយរូប ឱ្យទទួលជាអភិបាលស្រុកស្តីទី។ ប្រសិនបើអភិបាលស្រុកអវត្តមានដោយពុំបានផ្ទេរសិទ្ធិអភិបាលរងស្រុកដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃប្រកាសតែងតាំងអភិបាលរងនៃគណៈអភិបាលស្រុក ត្រូវធ្វើជាអភិបាលស្រុកស្តីទី។ ក្នុងករណីអភិបាលស្រុកស្តីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងស្រុកមួយរូប ឱ្យទទួលជាអភិបាលស្រុកស្តីទី និងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីធ្វើសេចក្តីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

---

[16] សៀវភៅ សមត្ថ និងរបៀបរបបនៅរដ្ឋបាលថ្នាក់ក្រោមជាតិ , និពន្ធដោយ អនុបណ្ឌិត ហៀង សាង និង អនុបណ្ឌិត ម៉េង ឆុង ឆ្នាំ២០១១

## ២.៤. មុខងាររបស់រដ្ឋបាលស្រុក

សាលាស្រុក គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក ដែលត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ។ រដ្ឋបាលស្រុកនីមួយៗត្រូវធ្វើជាម្ចាស់ហើយ និងទទួលខុសត្រូវរាល់ការចាត់ចែងលើលិខិតស្នាមឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវឱ្យស្របតាមច្បាប់ជាធរមាន។

រដ្ឋបាលស្រុកត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានផ្ទេរពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។[17]

មុខងារពាក់ព័ន្ធនិងការផ្ដល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានក្នុងវិស័យនីមួយៗត្រូវបានប្រគល់និងប្រតិភូកម្មទៅឱ្យរដ្ឋបាលស្រុកដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ១៨៤ អនក្រ.បកចុះថ្ងៃទី០២ ធ្នូ ឆ្នាំ ២០១៩។[18] លើកលែងតែមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលស្រុកនានាមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យនេះ។ មុខងារផ្ដល់សេវាសាធារណៈ និងអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលស្រុករួមមានមុខងារដូចជាកាតព្វកិច្ច និងមុខងារជាជម្រើស។ រដ្ឋបាលស្រុកត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រាន់ ការចាត់ចែង និងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវា និងធនធានដែលបានផ្ទេរមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានរបស់ខ្លួន ឬធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីអនុវត្តមុខងារជាកាតព្វកិច្ចទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព។ គោលការណ៍នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចត្រូវរៀបចំនិងធ្វើកំណត់ដោយក្រសួង ស្ថាប័ន នៃវិស័យនីមួយៗ។

រដ្ឋបាលស្រុកមានស្វ័យភាពក្នុងការសម្រេចជ្រើសរើស ឬមិនជ្រើសរើសយកមុខងារជាជម្រើសណាមួយមកអនុវត្តផ្អែកតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលស្រុកមានសិទ្ធិសម្រេចអំពីរបៀបគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដោយអនុលោមបទដ្ឋាន និងនីតិវិធីដែលមានក្នុងច្បាប់ ឬព្រះរាជក្រឹត្យ ឬប្រកាស ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវត្រួតពិនិត្យមើលឡើងវិញនូវមុខងារនានារបស់ខ្លួន ដើម្បីបន្តផ្ទេរមុខងារសមស្របទៅឱ្យរដ្ឋបាលស្រុកទៅតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

[17] សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបរបបការងាររដ្ឋបាលស្រុក ២០១០

[18] អនុក្រឹត្យលេខ១៨៤ អនក្រ ប.កចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

## ២.៥. ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក

ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក មានដូចខាងក្រោម៖

- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាស្រុកបានសម្រេចរួចហើយគណៈអភិបាលស្រុកត្រូវទទួលខុសត្រូវចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សាស្រុករបស់ខ្លួន។ ដូច្នេះគណៈអភិបាលស្រុក គឺជាអ្នកអនុវត្តទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក។
- ក្រុមប្រឹក្សាស្រុកត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលស្រុកដើម្បីធានាថាគណៈអភិបាលស្រុកអនុវត្តកិច្ចការទាំងនោះឱ្យបានត្រឹមត្រូវទៅតាមច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាស្រុក។
- គណៈអភិបាលស្រុក ត្រូវធ្វើសេចក្តីរាយការណ៍ផ្តល់ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក
- គណៈអភិបាលស្រុកត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុក និងរបស់ខ្លួនអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក និងមានគណនេយ្យភាពចំពោះ រាជរដ្ឋាភិបាល អំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។
- ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលស្រុក ក្នុងនាមជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុកអាចតម្រូវឱ្យអភិបាលស្រុកធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក។
- ក្រុមប្រឹក្សាស្រុកអាចផ្តល់អនុសាសន៍ និងការណែនាំដល់អភិបាលស្រុកអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។

## ២.៦. ការបង្កើតការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ការិយាល័យប្រជាពលរដ្ឋ ត្រូវបានបង្កើតឡើងសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។[19] ការិយាល័យប្រជាពលរដ្ឋដឹកនាំដោយប្រធាន (០១)រូប និងមានបុគ្គលិកមួយចំនួនជាជំនួយការ។

[19] មាត្រា៣១ នៃអនុក្រឹត្យ១៩ អនក្រ.បក ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### ២.៦.១ តួនាទី ភារកិច្ចរបស់ការិយាល័យរបស់ប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌមានភារកិច្ចដូចខាងក្រោម៖

- ប្រមូល និងទទួលពាក្យបណ្ដឹងនានាដែនសមត្ថកិច្ចរបស់ខ្លួន
- សម្រាំង និងវាយតម្លៃពាក្យបណ្ដឹងដែលទទួលបាន
- បញ្ជូនពាក្យបណ្ដឹងទាំងឡាយណាដែលមិនស្ថិតនៅដែនសមត្ថកិច្ចរបស់ខ្លួនទៅសមត្ថកិច្ចដែលពាក់ព័ន្ធ និងតាមដានដោះស្រាយដើម្បីបញ្ជូនព័ត៌មានទៅម្ចាស់ពាក្យបណ្ដឹង
- ចាត់វិធានការស៊ើបអង្កេតបណ្ដឹងរដ្ឋបាល លើកអនុសាសន៍អំពីវិធានការដោះស្រាយតាមដានអនុវត្តវិធានការដោះស្រាយបណ្ដឹងដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្ដល់ព័ត៌មានត្រឡប់ទៅដល់ប្រជាពលរដ្ឋអំពីលទ្ធផលនៃការដោះស្រាយពាក្យបណ្ដឹង
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយន្តការសម្រុះសម្រួលដោះស្រាយពាក្យបណ្ដឹងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន
- រាយការណ៍ជាប្រចាំអំពីលទ្ធផលនិងការដោះស្រាយពាក្យបណ្ដឹង។[20]

### ២.៦.២. សិទ្ធិអំណាចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌមានសិទ្ធិអំណាចដូចខាងក្រោម៖

- ប្រើប្រាស់បុគ្គលិក ថវិកា សម្ភារៈ និងមធ្យោបាយនានារបស់អង្គភាពខ្លួនសម្រាប់អនុវត្តសកម្មភាពផ្អែកតាមផែនការសកម្មភាពរបស់ខ្លួនដែលទទួលការអនុម័តពីក្រុមប្រឹក្សា
- ស៊ើបអង្កេតបណ្ដឹងដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ព្រមទាំងលើកអនុសាសន៍អំពីវិធានការដោះស្រាយប៉ុន្តែពុំមានសិទ្ធិចេញសេចក្ដីសម្រេចដើម្បីចាត់វិធានការដោះស្រាយ ឬដាក់ទណ្ឌកម្មឡើយ ស្នើសុំកិច្ចសហការឬការចូលរួមពីបុគ្គលិកនៃអង្គភាពនានានៃរដ្ឋបាលក្រុង ខណ្ឌ និងការិយាល័យអង្គភាពនានាតាមការចាំបាច់
- កោះអញ្ជើញបុគ្គលឬប្រធានអង្គភាពនានាដែលពាក់ព័ន្ធពាក្យបណ្ដឹងឱ្យចូលមកបំភ្លឺជាចាំបាច់
- ពិនិត្យមើលឯកសារ និងវត្ថុតាងផ្សេងៗដែលពាក់ព័ន្ធបណ្ដឹងនៅតាមអង្គភាពនានាដោយពុំចាំបាច់ជូនដំណឹងជាមុន និងដកហូតឯកសារនិងវត្ថុតាងទាំងនោះមករក្សាទុកតាមការចាំបាច់

---

[20] មាត្រា៣៣ នៃអនុក្រឹត្យ១៩ អនក្រ.បក ស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- រាយការណ៍ជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬមេឃុំចៅសង្កាត់អំពីការមិនសហការក្នុងស៊ើបអង្កេតរបស់ប្រធានអង្គភាព និងបុគ្គលដែលពាក់ព័ន្ធពាក្យបណ្ដឹង និងការមិនចាត់វិធានការដោះស្រាយពាក្យបណ្ដឹងនានាដែលពាក់ព័ន្ធអង្គភាពនានា។[21]

## ២.៧. ទំនាក់ទំនងរវាងរដ្ឋបាលស្រុក និងរដ្ឋបាលខេត្ត

ក្រៅពីទំនាក់ទំនងនានា ដែលត្រូវបានកំណត់ក្នុងតួនាទីភារកិច្ចនិងរបៀបរបបការងាររបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក រដ្ឋបាលខេត្ត រដ្ឋបាលស្រុកនៅមានទំនាក់ទំនងមួយចំនួនទៀតដូចជា៖

- ក្រុមប្រឹក្សាខេត្តត្រូវសហការជាមួយក្រុមប្រឹក្សាស្រុកក្នុងខេត្តរបស់ខ្លួនដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំក្នុងខេត្តរបស់ខ្លួនក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំ។
- គណៈអភិបាលខេត្ត គណៈអភិបាលស្រុក មានភារៈកិច្ចអនុវត្តកិច្ចការប្រចាំថ្ងៃក្នុងការទំនាក់ទំនងទៅវិញទៅមករវាងខេត្ត ស្រុក ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។
- ក្រុមប្រឹក្សាខេត្តត្រូវបានទទួលការធ្វើប្រតិភូកម្មអំណាចក្នុងនាមរាជរដ្ឋាភិបាល ដើម្បីផ្ដល់ការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាពលើសេចក្ដីសម្រេចនិងសកម្មភាពរបស់រដ្ឋបាលស្រុកដើម្បីធានាថារដ្ឋបាលស្រុកបំពេញមុខងារភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មស្របតាមរដ្ឋធម្មនុញ្ញនៃច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងស្របតាមគោលនយោបាយរបស់ជាតិ។
- ក្រុមប្រឹក្សាខេត្តត្រូវបំពេញតួនាទីខាងលើនេះលើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ស្រុកឱ្យស្របតាមគោលការណ៍នៃច្បាប់ស្ដីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ អនុក្រឹត លិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងការសម្រេចរបស់ គ.ជ.អ.ប។
- ក្រុមប្រឹក្សាខេត្តត្រូវបានទទួលប្រតិភូកម្មពីរាជរដ្ឋាភិបាលដើម្បីផ្ដល់ការគាំទ្រការសម្របសម្រួល និងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលស្រុក ដើម្បីរួមគ្នាសម្រេចឱ្យបាននូវគោលនយោបាយជាតិ។
- ក្រុមប្រឹក្សាខេត្តត្រូវធានាដារដ្ឋបាលស្រុកក្នុងខេត្ត បំពេញមុខងារ ភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ។
- ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ដែលមានព្រំប្រទល់ជាប់គ្នាត្រូវធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ និងធ្វើការសម្របសម្រួលជាមួយគ្នាលើមុខងារភារៈកិច្ចមួយ ឬច្រើន ដែលមានការពាក់ព័ន្ធគ្នា។

---

[21] មាត្រា៣៥ នៃអនុក្រឹត្យ១៩ អនក្រ.បក ស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ២.៨. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក

ក្រៅពីទំនាក់ទំនងនានាដែលបានកំណត់ក្នុងតួនាទីភារកិច្ច និងរបៀបរបបរបស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក រដ្ឋបាលស្រុកនៅមានទំនាក់ទំនងមួយចំនួនទៀតជាមួយរដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ដូចជា៖ **ការគាំទ្ររបស់រដ្ឋបាលស្រុកចំពោះឃុំ សង្កាត់** ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានជីវភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សាស្រុកត្រូវ៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុកឱ្យបង្កើត ជំរុញ និងធ្វើឱ្យមានការជីវភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- រួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជនក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់ក្នុងស្រុក
- ស្វែងយល់ និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងចំពោះសំណើរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក។[22]
- ដើម្បីឱ្យប្រឹក្សាឃុំក្រុមប្រឹក្សាសង្កាត់ក្នុងកស្រុកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលមុខងារ និងធនធានកាន់តែច្រើន។

ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធដើម្បី៖

- វាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំក្រុមប្រឹក្សាសង្កាត់នីមួយៗយ៉ាងហោចណាស់១ឆ្នាំម្តង
- ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់
- អប់រំ ផ្សព្វផ្សាយអំពីអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិតេយ្យ និងវិមជ្ឈការ វិសហមជ្ឈការដល់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋដំណើរការអភិបាលកិច្ចក្នុងស្រុក និងឃុំសង្កាត់ក្នុងស្រុក
- ផ្អែកលើការវាយតម្លៃសមត្ថភាព និងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាស្រុកត្រូវសម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាលធនធានផ្នែករដ្ឋបាលដែលចាំបាច់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ សំដៅធានាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ មានសមត្ថកិច្ច។

## ២.៩. របបហិរញ្ញវត្ថុរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវមានធនធានហិរញ្ញវត្ថុសមស្របដើម្បី៖

- គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន

[22] សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបរបបការងាររដ្ឋបាលស្រុក ២០១០

- ធ្វើការជ្រើសរើសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសរបស់ខ្លួន
- អនុវត្តតួនាទី ភារកិច្ចតាមច្បាប់ដែលកំណត់
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន
- អនុវត្តមុខងារ ភារកិច្ច សម្រាប់ជំរុញការអនុវត្តតាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ២.៩.១. ប្រភពចំណូល

ក្រុមប្រឹក្សា មានសិទ្ធិទទួលបានចំណូល ពីប្រភពនៅមូលដ្ឋាន ពីប្រភពនៅថ្នាក់ និងប្រភពផ្សេងទៀត ដោយអនុវត្តលោមតាមច្បាប់ស្តីពីរបបរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

❖ **ប្រភពចំណូលនៅមូលដ្ឋានរួមមាន៖**

- ពន្ធនៅមូលដ្ឋាន
- ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងៗ
- អំណោចស្ម័គ្រចិត្ត
- ចំណូលរបស់ក្រុមប្រឹក្សាស្រុកបានមកពីពន្ធ ឈ្នួល និងកម្រៃដែលត្រូវចែករំលែករវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក
- ប្រភពផ្សេងៗទៀតដែលបានកំណត់ដោយច្បាប់ឬអនុក្រឹត្យពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។[23]

❖ **ចំណូលពីថ្នាក់ជាតិរួមមាន**

- មូលនិធិផ្ទេរពីថវិការរដ្ឋ
- ចំណូលចែករំលែក
- ចំណូលថ្លៃសេវាបានមកពីមុចងារដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង។[24]

### ២.៩.២. ការិយាល័យចំណុះស្រុកបាធាយ

សាលាស្រុកបាធាយ មានការិយាល័យចំណុះចំនួន១៣ ដូចជា៖

១. ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង

២. ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

៣. អង្គភាពលទ្ធកម្ម

៤. ការិយាល័យគ្រប់គ្រងធនធានមនុស្ស

---

[23] មាត្រា២៤៧ នៃច្បាប់និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[24] មាត្រា១៨ នៃច្បាប់និងច្បាប់វិសោធនកម្មស្តីពីការគ្រប់គ្រងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

៥. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់

៦. ការិយាល័យលេខាធិការក្រុមប្រឹក្សា

៧. ការិយាល័យអប់រំ យុវជន និងកីឡា

៨. ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

៩. ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន

១០. ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន

១១. ការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍

១២. ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម

១៣. ការិយាល័យច្រកចេញចូលតែមួយ។

ការិយាល័យនីមួយៗដឹកនាំដោយប្រធានការិយាល័យមួយរូប និងមានអនុប្រធានការិយាល័យមួយរូបជាជំនួយការ។ ប្រធានការិយាល័យនីមួយៗត្រូវមានការទទួលខុសត្រូវ និងត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាស្រុក។[25]

**១. តួនាទី ភារកិច្ច ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង**

- ត្រួត្យពិនិត្យលើការអនុវត្តតាមច្បាប់ ដីកា លិខិតបទដ្ឋានគតិយុត្ត
- ត្រួតពិនិត្យលើការងាររដ្ឋបាល ការងារបុគ្គលិក ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ
- ត្រួតពិនិត្យការអនុវិស័យ បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងម៉ោងបំពេញការងារ។

**២. តួនាទី ភារកិច្ចការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

- ការងារនីត្យានុកូដ្ឋាន
- គ្រប់គ្រង និងថែរក្សាត្រា
- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័នរបស់រដ្ឋបាលស្រុក
- ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុ
- ការងារសណ្តាប់ធ្នាប់សាធារណៈ។

**៣. តួនាទី ភារកិច្ចការិយាល័យ អង្គភាពលទ្ធកម្ម**

- រៀបចំផែនការលទ្ធកម្ម
- រៀបចំឯកសាដេញថ្លៃ ផ្សព្វផ្សាយ ទុកដាក់ឯកសារសំណើដេញថ្លៃ
- រៀបចំរបាយការណ៍ និងកំណត់ហេតុ

[25] អគ្គការលេខរបស់រដ្ឋបាលស្រុកបាធាយ ឆ្នាំ២០២២

- រៀបចំនិងសម្រួលសម្រួលការដេញថ្លៃ
- ផ្សព្វផ្សាយផលិតផលការដេញថ្លៃ
- តាមដានអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តលទ្ធផល។

**៤. តួនាទី ភារកិច្ច ការិយាល័យគ្រប់គ្រងធនធានមនុស្ស**

- គ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិក
- បណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក
- គ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធ
- ការផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។

**៥. តួនាទី ភារកិច្ច ការិយាល័យផែនការ និងការគាំទ្រឃុំ សង្កាត់**

- រៀបចំនិងអនុវត្តផែនការអភិវឌ្ឍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល
- រៀបចំផែនការសកម្មភាព ថវិការប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍនានា
- ការងារស្ថិតិប្រជាជន
- បណ្តុះបណ្តាលសមត្ថភាពបុគ្គលិក
- គាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ
- ដោះស្រាយសំណើ និងសូមណ្ឌមពរ និងបញ្ហាប្រឈមនានា។

**៦. តួនាទី ភារកិច្ច ការិយាល័យការិយាល័យលេខាធិការក្រុមប្រឹក្សា**

- រៀបចំប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- រៀបចំកំណត់ហេតុនៃការប្រជុំនានារបស់ក្រុមប្រឹក្សា
- រៀបចំវេទិការផ្សព្វផ្សាយ និងពិគ្រោះយោបល់
- គ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារ
- បិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានា។

**៧. តួនាទី ភារកិច្ច ការិយាល័យអប់រំ យុវជន និងកីឡា**

- ការគ្រប់គ្រងការអប់រំកុមារតូចៗ
- ការគ្រប់គ្រង ការអប់រំបឋមសិក្សា
- ការគ្រប់គ្រងប្រព័ន្ធអប់រំក្រៅប្រព័ន្ធ
- ការគ្រប់គ្រងគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះដឹងទូទៅ

- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា។

## ៨. ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

- ការរៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារសំណង់
- ការងារលំនៅដ្ឋាន។

## ៩. ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន

- សិក្សា ស្រាវជ្រាវ ការរៀបចំ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត
- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ជូនប្រជាពលរដ្ឋ
- រៀបចំការបណ្តុះបណ្តាលជំនាញសម្រុះសម្រួលវិវាទនៅមូលដ្ឋាន
- ពិនិត្យនីត្យានុកូលភាពលើដីការ និងសេចក្តីសម្រេចនានា
- ដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានា។

## ១០. ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន

- ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការងារធនធានទឹក
- ការគ្រប់គ្រងប្រព័ន្ធតំបន់ការងារធម្មជាតិ
- ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ ប្រព័ន្ធប្រតិកម្មទឹកកខ្វក់។

## ១១. ការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍

- ការងារសាធារណៈការ និងដឹកជញ្ជូន
- ការងារឧស្សាហកម្ម និងសប្បិកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារអភិវឌ្ឍន៍ជនបទ
- ការងារពាណិជ្ជកម្ម

- ការងារប្រៃសនីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍន៍សហគមន៍។

**១២. ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**

- ការងារសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា
- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោងមហន្តរាយ។

**១៣. ការិយាល័យច្រកចេញចូលតែមួយ**

- ការទទួល និងការផ្តល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋ
- ការប្រមូល និងការបង់កម្រៃសេវារដ្ឋបាលតាមគោលការនិងនីតិវិធីកំណត់
- ការផ្តល់ព័ត៌មាននានា និងផ្សព្វផ្សាយជាសាធារណៈ
- ការទុកដាក់ ការថែរក្សា ការគ្រប់ឯកសារនានា។[26]

### ២.៩.៣. ការគ្រប់គ្រងធនធានមនុស្សរដ្ឋបាលស្រុកបាធាយ

រដ្ឋបាលស្រុកបាធាយ មានក្រុមប្រឹក្សាចំនួន ២១រូប ស្រី ០៣រូប ប្រុស១៨រូប។ គណៈអភិបាលមានចំនួន ០៥រូប ស្រី ០១រូប ប្រុស ០៤រូប នាយករដ្ឋបាលមានចំនួន ០១ ប្រុស នាយករងមានចំនួន ០២ ប្រុស ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុមានចំនួន ០២ប្រុស។

ជាមួយគ្នានេះផងដែល រដ្ឋបាលស្រុកបាធាយបានយកចិត្តទុកដាក់យ៉ាងខ្លាំងជាមួយ និងការគ្រប់គ្រងធនធានមនុស្សទាំងថ្នាក់ដឹកនាំរដ្ឋបាលស្រុក ហើយនិងមន្រ្តីសាលាស្រុក ដើម្បីសម្រេចឱ្យបាននូវលទ្ធផលរំពឹងទុករបស់រដ្ឋបាលស្រុកបាធាយ។ ដើម្បីគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលស្រុកបាធាយឱ្យមានប្រសិទ្ធភាពរដ្ឋបាលស្រុកបាធាយបានរៀបចំថ្នាក់ដឹកនាំ និងមន្ត្រីដូចតទៅ ៖ ប្រធានក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) អភិបាល អភិបាលរង នាយករដ្ឋបាល ប្រធានការិយាល័យនិងអង្គភាពអនុប្រធានការិយាល័យ និងអង្គភាពមន្ត្រីការិយាល័យ និងបុគ្គលិកកិច្ចសន្យា។[27]

---

[26] អគ្គការលេខរបស់រដ្ឋបាលស្រុកបាធាយ ឆ្នាំ២០២២

[27] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

### ២.៩.៤. ផែនការអភិវឌ្ឍប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

មាត្រា៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថាក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ (៥)ឆ្នាំដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំតាមរយៈការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិល។ ក្រោយចូលកាន់តំណែងក្រុមប្រឹក្សាត្រូវខិតខំរៀបចំផែនការអភិវឌ្ឍប្រាំឆ្នាំរបស់ខ្លួនឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងយ៉ាងយូរនៅក្នុងឆ្នាំទី២ នៃអាណត្តិរបស់ខ្លួន។ ផែនការអភិវឌ្ឍនេះត្រូវអនុវត្តតាមការកំណត់របស់កម្មវិធីវិនិយោគបីឆ្នាំរំកិលដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ផែនការអភិវឌ្ឍប្រាំឆ្នាំ គឺជាចក្ខុវិស័យរបស់ក្រុមប្រឹក្សាស្រុកដែលបានកំណត់អំពីរូបភាពនៃការអភិវឌ្ឍនៅក្នុងមូលដ្ឋាននៃដែនសមត្ថកិច្ចរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាស្រុកចង់ឃើញ និងចង់សម្រេចឱ្យបាននៅ ចុងអាណត្តិឆ្នាំរបស់ក្រុមប្រឹក្សាដោយឈរលើមូលដ្ឋានធនធាននិងសក្តានុពលរបស់រដ្ឋបាលដែនដីរបស់ខ្លួន។

ផែនការអភិវឌ្ឍប្រាំនេះមានរយៈពេលដូចអាណត្តិរបស់ក្រុមប្រឹក្សាដែរវាជាមធ្យាបាយមួយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវប្រើប្រាស់សម្រាប់កំណត់ អំពីបញ្ហា តម្រូវការ និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ចំណែកឯកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលគឺជាការធ្វើឱ្យខ្លឹមសារនៃការកសាងផែនការអភិវឌ្ឍស្រុកទៅជាគម្រោងសកម្មភាពឬសេវាកម្មជាក់ស្តែងដោយមានការភ្ជាប់នូវចំណាយមូលនិធិសំដៅ-លើកកម្ពស់នៃការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍនៅស្រុកសម្រាប់រយៈពេលបីឆ្នាំ។

### ២.៩.៥. គោលការណ៍សំខាន់ៗនៃការកសាងផែនការអភិវឌ្ឍប្រាំឆ្នាំ

ដើម្បីធានាថាតម្រូវការ បញ្ហា និងក្តីកង្វល់របស់ប្រជាពលរដ្ឋត្រូវបានឆ្លើយតបនិងដោះស្រាយនៅក្នុងការកសាងផែនការអភិវឌ្ឍប្រាំឆ្នាំរបស់រដ្ឋបាលស្រុក ក្រុមប្រឹក្សាត្រូវណែនាំគណៈអភិបាល និងក្រុមការងារកសាង។ ផែនការអភិវឌ្ឍប្រាំឆ្នាំ ឱ្យយកចិត្តទុកដាក់ក្នុងការរៀបចំកិច្ចការនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយត្រូវផ្អែកតាមគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- តម្លាភាព
- អង្គតិភាព និងសុខុដុមនីយកម្ម
- ការចែករំលែកព័ត៌មាន
- ការចូលរួមពិគ្រោះយោបល់ទូទៅ
- ការឆ្លើយតបនិងតម្រូវការ
- ប្រសិទ្ធភាព និងសុក្រឹតភាព
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ការធានាសមធម៌
- ធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន។

### ២.៩.៦. ដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍប្រាំឆ្នាំរបស់រដ្ឋបាលស្រុកបាធាយ

ខាងក្រោមនេះ ជាសេចក្ដីសង្ខេបនៃដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍប្រាំឆ្នាំរបស់រដ្ឋបាលស្រុកបាធាយដែលមាន៣ជំហាន ដូចខាងក្រោម៖

**ជំហានទី១៖** ការរៀបចំនិងផ្សព្វផ្សាយស្ដីពីការរៀបចំផែនការអភិវឌ្ឍស្រុកជំហាននេះមានដំណាក់កាលនិងសកម្មភាពដូចខាងក្រោម៖

- ដំណាក់កាលមុនកិច្ចប្រជុំផ្សព្វផ្សាយ
- ដំនាក់កាលក្រោយប្រជុំផ្សាព្វផ្សាយ
- ដំណាក់កាលក្រោយកិច្ចប្រជុំផ្សព្វផ្សាយ។

**ជំហានទី២៖** ការរៀបចំ និងការចងក្រងសេចក្ដីព្រាងផែនការអភិវឌ្ឍរាជធានី ជំហាននេះមានដំណាក់កាលនិងសកម្មភាពដូចខាងក្រោម៖

- ការវិភាគស្ថានភាព
- ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ
- ការរៀបចំសេចក្ដីព្រាងក្របខណ្ឌអភិវឌ្ឍន៍
- ការពិនិត្យ និងការផ្ដល់យោបល់នៃគណៈអភិបាល
- ការរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃ
- ការចងក្រងសៀវភៅផែនការអភិវឌ្ឍ
- ការរៀបចំខ្លឹមសារស្ថានភាពសង្គមសេដ្ឋកិច្ច
- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីផែនការអភិវឌ្ឍ។

**ជំហានទី៣៖** ការពិនិត្យអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍស្រុក ជំហាននេះមានបីដំណាក់កាលនិងសកម្មភាពដូចខាងក្រោម៖

- ការអនុម័តផែនការអភិវឌ្ឍស្រុក
- ការបោះពុម្ពនិងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍស្រុក។[28]

[28] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

### ២.៩.៧. ដំណើរការរៀបចំ និង កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ខាងក្រោមនេះ ជាសេចក្តីសង្ខេបនៃដំណើរការរៀបចំ និងការកសាងផែនការវិនិយោគបីឆ្នាំរំកិលរបស់ស្រុកបាធាយ ដែលមានបីជំហានដូចខាងក្រោម៖

**ជំហានទី១៖** ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ស្រុក ជំហាននេះមានសកម្មភាពដូចខាងក្រោម៖

- ប្រជុំណែនាំអំពីការប្រមូលតម្រូវការអទិភាព
- ប្រជុំបូកសរុប និងរៀបបញ្ជី គម្រោង និងសកម្មភាពអាទិភាព។

**ជំហានទី២៖** ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ស្រុកដែលជំហាននេះមានសកម្មភាពដូចខាងក្រោម៖

- ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅតាមបណ្តាលស្រុក
- កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងចាត់អាទិភាពគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរិកិល
- ការធ្វើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការរៀបចំតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**ជំហានទី៣៖** ការពិនិត្យអនុម័ត និងការផ្សព្វផ្សាយសៀវភោកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលជំហាននេះមានសកម្មភាពដូចខាងក្រោម៖

- កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរិល។

### ២.៩.៨. ថវិការបស់រដ្ឋបាលស្រុក

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា៤៤ ចែងថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានថវិកាផ្ទាល់របស់ខ្លួនដែលហៅថាថវិការរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រង និងការអនុវត្តលើថវិការប្រចាំឆ្នាំផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

❖ **ចំណូលដែលរដ្ឋបាលស្រុកទទួលបានមានដូចខាងក្រោម៖**

- ចំណុះនៃមូលនិធិបម្រុង
- ការឧបត្ថម្ភអំណាយ
- ចំណូលសារពើពន្ធ

- ផលទុននៃទ្រព្យសម្បត្តិរដ្ឋ
- ផលទុននៃការជួលទ្រព្យសម្បត្តិរដ្ឋនិងសេវា
- ឧបត្ថម្ភធនវិនិយោគ។

❖ **ការអនុវត្តចំណាយដែលរដ្ឋបាលស្រុកបានចំណាយមានដូចខាងក្រោម៖**

- សេវា និងការទិញ
- ពន្ធ និងអាករ
- អត្ថប្រយោជន៍សង្គម
- បន្ទុកបុគ្គលិក និងបន្ទុកហិរញ្ញវត្ថុ
- ឧបត្ថម្ភធន និងជំនួញសង្គម និងចំណាយដែលមិនបានគ្រោងទុក។[29]

[29] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

# ជំពូកទី៣

# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. សមិទ្ធិផលស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

### ៣.១.១. ស្ថានភាពសេដ្ឋកិច្ច

#### ក. វិស័យកសិកម្ម

ការផលិតស្បៀងប្រចាំគ្រួសារត្រូវពឹងផ្អែកទាំងស្រុងទៅលើដំណាំស្រូវ(ស្រែប្រាំងនិងវស្សា)ដោយប្រើប្រាស់ពូជក្នុងស្រុក និងពូជផលិតថ្មី។ បរិមាណផលិតផលស្រូវចន្លោះពីឆ្នាំ២០១៧ដល់ ឆ្នាំ២០២១ ស្មើនិង ប្រមាណ ៩៨ សែនតោនគឺរាប់បញ្ចូលទាំងស្រូវប្រាំង និងស្រូវវស្សា ទិន្នផលស្រូវគិតជាមធ្យមក្នុង១ហិកតា ស្មើ និង២.៦តោន ចំពោះស្រូវវស្សា និងស្រូវប្រាំងស្មើនិង ៣.៦តោន។ ការផ្គត់ផ្គង់ស្បៀងប្រចាំឆ្នាំសម្រាប់គ្រួសារ ប្រជាពលរដ្ឋមួយចំនួនមិនគ្រប់គ្រាន់ បើធៀបបរិមាណផលស្រូវប្រចាំឆ្នាំតាមបណ្ដាឃុំនីមួយៗ។ជាក់ស្ដែងកាលពី៥ឆ្នាំមុនមាន២ឃុំប៉ុណ្ណោះដែលផលិតស្បៀងលើសពីតម្រូវការហូបចុកគឺឃុំបាធាយនិងឃុំជាលា ប៉ុន្តែបច្ចុប្បន្ន មានឃុំចំនួន៤ទៀតដែលបានផលិតស្រូវ (ស្បៀង) គ្រប់តាមតម្រូវការគឺឃុំជើងព្រៃ, ឃុំមេព្រីង, ឃុំសំបូរ និង ឃុំតាំងក្រាំង។[30]

ប្រសិនបើគិតសរុប ពីបរិមាណផលស្រូវក្នុងស្រុកទាំងមូលគឺអាចរ៉ាប់រងបាននូវតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ក្នុងស្រុក ប៉ុន្តែបើពិនិត្យតាមបណ្ដាឃុំដែលផលិតស្បៀងបានច្រើន ក៏មានការចំណាយច្រើនដែរដើម្បីទាញយកទិន្នផលស្រូវសម្រាប់លក់ចេញដោះស្រាយជីវភាពក្នុងតម្រូវការគ្រួសារ។ ដូចនេះសម្រាប់មូលដ្ឋានឃុំប្រមាណ ៥០% ទៀតនៅមិនទាន់មានការផលិតស្បៀងបានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការហូបចុកនៅឡើយដែលបញ្ហាទាំងនេះ បណ្ដាលមកពីការធ្វើដំណាំកសិកម្មរបស់កសិករភាគច្រើនចំណុះនិងធម្មជាតិគឺស្រូវវស្សាពឹងផ្អែកលើទឹកភ្លៀងឯស្រូវប្រាំងពឹងផ្អែកលើទឹកជំនន់ទន្លេមេគង្គហូរចូល បើពុំនោះទេដំណាំស្រូវរបស់ប្រជាកសិករនិងមិនសង្ឃឹមថា ទទួលបានទិន្នផលល្អឡើយ។ រីឯប្រព័ន្ធស្រោចស្រពមានគ្រួសារកសិករចំនួន ៥៥%ប៉ុណ្ណោះដែលមានលទ្ធភាពបានប្រើប្រាស់ប្រពន្ធស្រោចស្រពដំណាំស្រូវ។ កម្ពស់ទឹកភ្លៀងសម្រាប់ឆ្នាំ២០១៧ដល់ ឆ្នាំ២០២១នេះស្រុកបាធាយទទួលបានចំនួនប្រមាណ ៧៣០ម.ម ដែលជាកម្រិតទឹកភ្លៀងមិនអាចធានាបន្ថែមដល់ការស្រោចស្រពដំណាំស្រូវបានឡើយ។

ស្រុកភាគច្រើនចិញ្ចឹមត្រីតាមស្រះជាលក្ខណៈផ្គត់ផ្គង់គ្រួសារ និងការផ្គត់ផ្គង់ទីផ្សារហើយការចិញ្ចឹមត្រីតាមស្រះចំនួន ៥៦៩ស្រះ ស្មើនិង ៥៥០គ្រួសារ។

ការចិញ្ចឹមគោ ក្របីរបស់កសិករគឺជាចិញ្ចឹមយកសាច់មានលក្ខណៈតិចតួចចំណែកឯការចិញ្ចឹមទាជាលក្ខណៈគ្រួសារសម្រាប់យកសាច់និងស៊ុតសម្រាប់ផ្គត់ផ្គង់គ្រួសារ និងទីផ្សារបានមួយចំណែកផងដែលក្នុងនោះដែលគ្រួសារកសិករចិញ្ចឹមទា១០០០គ្រួសារគឺស្មើរតែគ្រប់ឃុំទៅហើយ។

[30] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

❖ បញ្ហាប្រឈម

- ទិន្នផលស្រូវវស្សាទាប (ខ្វះបច្ចេកទេស និងភាពយឺតយ៉ាវនៃការដាំដុះ)
- ដំណាំស្រូវមានសត្វល្អិតបំផ្លាញ និងដីគ្មានជីវជាតិ
- ទំនប់ធារាសាស្ត្រមានតិក (ខូចខាត មិនរឹងមាំ និងប្រឡាយរាក់)
- ភាគច្រើនជាធារាសាស្ត្រតូចៗ មិនអាចផ្គត់ផ្គង់ទឹកដល់ដំណាំស្រូវបានគ្រប់គ្រាន់
- ការប្រើប្រាស់ជីធម្មជាតិតិច (ប្រើជីគីមីច្រើន និងតម្លៃខ្ពស់)
- ទឹកជំនន់ទន្លេមេគង្គមិនទៀងទាត់ នាំឱ្យជួបគ្រោះធម្មជាតិ
- ប្រេងឥន្ធនៈថ្លៃ (រដូវបង្កបង្កើនផល)
- ប្រមូលធនធានមច្ឆាតូចៗ យ៉ាងច្រើន សម្រាប់ផ្គត់ផ្គង់ការចិញ្ចឹមត្រីឆ្តោរ។

❖ ដំណោះស្រាយ

- ជំរុញល្បឿននៃការដាំដុះឱ្យទាន់រដូវកាល
- ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ និងធ្វើស្រែបង្ហាញ (ពូជ)
- អប់រំកាត់បន្ថយការប្រើជីគីមី និងបំផុសការសន្សំជីធម្មជាតិ
- ពង្រឹង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងធារាសាស្ត្រ
- បង្កើនការអប់រំដល់សហគមន៍នេសាទ និងសហគមន៍ប្រើប្រាស់ទឹក
- បណ្តុះបណ្តាលបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ
- ណែនាំប្រជាពលរដ្ឋលុបបំបាត់ ឬកាត់បន្ថយការចិញ្ចឹមត្រីឆ្តោរ។

## ខ. វិស័យធនធានទឹក

ស្រុកបាធាយពឹងផ្អែកលើការងារកសិកម្មជាពិសេសការបង្កបង្កើនផលស្រូវប្រាំង និងស្រូវវស្សាក្នុងនោះទាមទារនូវប្រភពទឹកដើម្បីស្រោចស្រពដំណាំកសិកម្ម។ក្នុងស្ថានភាពបច្ចុប្បន្នស្រុកបាធាយមានប្រឡាយចំនួន១២ខ្សែនិងទំនប់ចំនួន៧ក្នុងឆ្នាំ២០១១ ជួបគ្រោះមហន្តរាយដោយសារទឹកជំនន់បានធ្វើឱ្យទំនប់ប្រឡាយមានការខូចខាតអស់ជាច្រើនដែលទាមទារឱ្យមានការស្តារឡើងវិញ។

❖ បញ្ហាប្រឈម

- ខ្វះទឹកស្រោចស្រព និងប្រឡាយរាក់
- ទំនប់ដាច់ ឬបាក់ដោយសារទឹករលក និងទំនប់ទាប
- ប្រជាកសិករដណ្តើមទឹកគ្នាសម្រាប់ស្រោចស្រព។

❖ **ដំណោះស្រាយ**

➢ ចលនាប្រជាពលរដ្ឋថែទាំទំនប់ និងប្រឡាយទឹក

➢ ស្តារប្រឡាយ និងជួសជុលទំនប់ ព្រមទាំងរៀបចំសហគមន៍ប្រើប្រាស់ទឹក។

## គ. វិស័យពាណិជ្ជកម្ម

សកម្មភាពនៃការដោះដូរទំនិញនៅក្នុងស្រុកសង្កេតឃើញថា មានចរន្តទំនាក់ទំនងនៅផ្សារផ្កាវ ដែលបើកលក់ដូរពេញមួយថ្ងៃ ដែលបាននិងកំពុងផ្តល់សេវាដោះដូរទំនិញ ទាំងផលិតផលក្នុងស្រុក និងក្រៅស្រុក។ ទំនិញភាគច្រើននាំចូលក្នុងទីផ្សារបម្រើឱ្យតម្រូវការរបស់ប្រជាពលរដ្ឋ។ ចំពោះទំនិញទាំងនេះគឺនាំយកពីភ្នំពេញ ដូចជាគ្រឿងឧបភោគបរិភោគរបស់របរប្រើក្នុងផ្ទះគ្រឿងអេឡិចត្រូនិច ប្រេងឥន្ធនៈ និងគ្រឿងសំណង់ជាដើម។

ផលិតផលដឹកនាំចេញក្រៅស្រុកផលិតផលកសិកម្ម **(ស្រូវអង្ករកន្ទក់ស៊ុតទាត្រីស្រស់និងស្ករត្នោត)** និងមួយចំនួនទៀតដូចជាថ្មសំណង់ និងគ្រឿងចម្លាក់ថ្ម។

❖ **បញ្ហាប្រឈម**

➢ ផលិតផលក្នុងស្រុកខ្វះទីផ្សារ

➢ ផលិតផលខុសពីតម្រូវការទីផ្សារ និងមិនមានលក្ខណៈស្តង់ដារ។

❖ **ដំណោះស្រាយ**

➢ អប់រំណែនាំប្រជាពលរដ្ឋប្រើប្រាស់ពូជដែលជាតម្រូវការទីផ្សារ

➢ ខិតខំស្រាវជ្រាវរកទីផ្សារផលិតផល និងវេចខ្ចប់តាមតម្រូវការទីផ្សារ

➢ សម្របសម្រួលការផលិតឱ្យត្រូវតាមស្តង់ដារ។

## ឃ. វិស័យឧស្សាហកម្ម

កាលពី១០ឆ្នាំមុន សកម្មភាពតបណ្តាញអគ្គីសនីដល់មូលដ្ឋានបានប្រើប្រាស់ប្រហែល ១៥.៤៣% នៃគ្រួសារសរុប ស្មើនិង ៣៥៥៤គ្រួសារតែប៉ុណ្ណោះ។ មកដល់ឆ្នាំ២០១៧ ដល់ ឆ្នាំ២០២១ នេះស្រុកបានជំរុញឱ្យក្រុមហ៊ុនអគ្គិសនីឯកជនតបណ្តាញអគ្គិសនីជាបន្តបន្ទាប់ឱ្យដល់មូលដ្ឋាន ឃុំ ជាច្រើនហើយដែលក្នុងនោះតួលេខសរុបនៃប្រជាពលរដ្ឋបានប្រើប្រាស់អគ្គីសនីចំនួនប្រមាណ១៣,៩៣៧គ្រួសារ ស្មើនិង ៥៧.២%នៃគ្រួសារសរុប។ ប្រាំឆ្នាំបន្តទៀត ស្រុកនិង ព្យាយាមទំនាក់ទំនងឱ្យបានអគ្គីសនីប្រើប្រាស់ស្ទើរគ្រប់ភូមិក្នុងស្រុកបាធាយ។

សហគ្រាសផលិតថ្មសំណង់មាន ៤មូលដ្ឋាន **(ឃុំតាំងក្រាំង និងឃុំជាលា)** សហគ្រាសផលិតថ្មសំណង់សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងនាំចេញ **(ក្រុមហ៊ុន សុខ សុខា និងក្រុមហ៊ុន ម៉ៃ ដា)** រីឯសហគ្រាសផលិតសម្រាប់សាងសង់ផ្លូវ ថ្នល់ ស្ពានដែលមានកិច្ចសន្យាដោយរាជរដ្ឋាភិបាលកម្ពុជា(**កងវិស្វកម្ម**)។

សហគ្រាសមួយទៀតគឺរបស់ **ក្រុមហ៊ុន សៀង ហៃ គ្រុប** ដែលជាក្រុមហ៊ុនចិនទទួលបានការដេញថ្លៃអនុវត្តសាងសង់ផ្លូវជាតិលេខ 6A និងលេខ 6 ស្ថិតនៅឃុំជាលាដែលកំពុងមានសកម្មភាពគួរឱ្យកត់សំគាល់ ស្របគ្នានិងឆ្នាំ ២០១៧-២០១៨ នេះ រាជរដ្ឋាភិបាលកំពុងសស្រាក់សស្រាំក្នុងការសាងសង់ពង្រីកផ្លូវជាតិនានា។ សហគ្រាសផលិតទឹកស្អាតមាន ៣កន្លែង គឺនៅឃុំផ្អាវ ឃុំបាធាយ និងឃុំតាំងក្រាំង។ជាលទ្ធផលត្រឹមឆ្នាំ ២០១៧នេះសហគ្រាសបានផ្គត់ផ្គង់ទឹកដល់ប្រជាពលរដ្ឋសរុបទាំង ៣ទីតាំងបានចំនួន ១៦៦០១គ្រួសារ។

- **បញ្ហាប្រឈម**
  - ផលិតថាមពលប្រើប្រាស់មិនទាន់គ្រប់គ្រាន់តាមតម្រូវការរបស់ប្រជាពលរដ្ឋ
  - មូលដ្ឋានឃុំមួយចំនួននៅប្រើប្រាស់អគ្គីសនីឯកជន **(វត្ថុធាតុដើមតម្លៃខ្ពស់)**
  - មានការត្អូញត្អែរពីប្រជាពលរដ្ឋអ្នកប្រើប្រាស់ភ្លើងថា គីឡូដើរលឿន **(ស៊ីភ្លើងច្រើន)**។
- **ដំណោះស្រាយ**
  - សម្របសម្រួលការងារបច្ចេកទេសជាមួយអ្នកវិនិយោគទុន **(ល្បឿនកុងទ័រ)**
  - ជំរុញសកម្មភាពតបណ្តាញអគ្គិសនី និងទឹកស្អាតដល់មូលដ្ឋានភូមិ ឃុំថែមទៀត។[31]

**ង. វិស័យគមនាគមន៍**

គិតមកដល់ឆ្នាំ ២០២២ នេះ ស្រុកបាធាយបានទទួលផ្លូវកៅស៊ូចំនួន ៥ខ្សែ ដែលជាផ្លូវឆ្លងកាត់ពីឃុំមួយទៅឃុំដទៃទៀតក្នុងស្រុក និងក្រៅស្រុក ប្រវែងសរុប ៥៧គ.ម និងផ្លូវកៅស៊ូ ២ខ្សែទៀតដែលជាខ្នាតផ្លូវជាតិគឺ ផ្លូវលេខ ៦១ ប្រវែង ១២គ.ម ដែលបានសាងសង់រួចជាស្ថាពរ និងកំណាត់ផ្លូវជាតិលេខ ៦ និង ៦A ប្រវែងសរុប ២៣គ.មដែលក្រុមហ៊ុនសៀងហៃបានចាក់ក្រាលកៅស៊ូបញ្ចប់ការស្ថាបនារួចរាល់ក្នុងឆ្នាំនិង២០១៥។ នៅឆ្នាំ១០១៨គម្រោងរបស់ខេត្តបានសាងសង់ផ្លូវបេតុងប្រវែង១៨០០ម៉ែត្រពីឃុំទំនប់ទៅឃុំតាំងក្រសាំង។ និង៣ខ្សែពីផ្សាផ្អាវទៅឃុំត្រប់ប្រវែង១៨គីឡូម៉ែត្រនិងពីឃុំផ្អាវកាត់តាមជឃុំមេព្រីងជើងព្រៃតាំងក្រសាំងទៅឃុំត្រប់២៥គីឡូម៉ែត្រ និងមួយខ្សែទៀតជាគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍខ្នាតតូចតំបន់ទន្លេសាបពីឃុំបាធាយទៅឃុំមេព្រីងនិងផ្លូវបេតុង៣ខ្សែប្រវែង២៣៧៣ម៉ែត្រនៅឃុំច្បារអំពៅឃុំតាំងក្រសាំងនិងឃុំតាំងក្រាំងនិងរៀបចំផ្លូវកៅស៊ូ៤ខ្សែទៀតមានឃុំជើងព្រៃឃុំសណ្តែកឃុំត្រប់និងឃុំទំនប់ប្រវែង៨៥០០ម៉ែត្រនៅឆ្នាំ២០១៩។

ក្រៅពីនេះ ជាគម្រោងមូលនិធិស្រុកដែលបានសាងសង់ផ្លូវបេតុងបានចំនួន១០ឃុំមានឃុំបាធាយប្រវែង ១០០០ម៉ែត្រ ឃុំជាលា៥០០ម៉ែត្រឃុំជើងព្រៃ១២០ម៉ែត្រ ឃុំមេព្រីង១២២ម៉ែត្រ ឃុំផ្អាវ៣០០ម៉ែត្រ ឃុំសំបូរ១២០ម៉ែត្រឃុំសណ្តែក១២១ម៉ែត្រ ឃុំតាំងក្រាំង២៥០ម៉ែត្រ ឃុំតាំងក្រសាំង១២០ម៉ែត្រ និងឃុំទំនប់ប្រវែង១៤០ម៉ែត្រនិងផ្លូវបេតុងអាមេ។

[31] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

តាមបណ្តាឃុំបានសាងសង់ជារៀងរាល់ឆ្នាំមានខ្វាត់ខ្វែងពាសពេញក្នុងឃុំនិមួយៗនិងផ្លូវក្រាលថ្មភ្នំ និងគ្រួសក្រហមស្ទើរគ្រប់ច្រកល្ហកដែលសមិទ្ធផលទាំងនេះបានបង្កលក្ខណៈងាយស្រួលយ៉ាងច្រើនដល់ប្រជាពលរដ្ឋក្នុងស្រុក។ ទោះជាយ៉ាងនេះក្តីក៏នៅមានផ្លូវលំមួយចំនួនទៀតដែលរងការខូចខាតយ៉ាងធ្ងន់ធ្ងរហើយដែលត្រូវបន្តជួសជុលឬកែសម្រួលទៅជាផ្លូវកៅស៊ូក្នុង អាណត្តិ ៥ឆ្នាំនេះ។

- **បញ្ហាប្រឈម**
  - រថយន្តផ្ទុកទម្ងន់ហួសពីសមត្ថភាពផ្លូវ និងផ្លូវតូចលំបាកជៀសគ្នា
  - ផ្លូវលំមួយចំនួនខូចខាតខ្លាំង និងច្រើនកន្លែងលំបាកធ្វើដំណើរ
  - ផ្លូវកៅស៊ូក្នុងឃុំគ្មានលូបង្ហូរទឹកគ្មានស្លាកសញ្ញាចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ញឹកញាប់
  - អ្នកបើកបរគ្មានប័ណ្ណបើកបរ មិនគោរពសិទ្ធិគ្នា និងមិនគោរពល្បឿនកំណត់។
- **ដំណោះស្រាយ**
  - ពង្រឹង និងបង្កើនការត្រួតពិនិត្យចរាចររបស់សមត្ថកិច្ច
  - អប់រំណែនាំផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ និងរៀនសូត្រយកប័ណ្ណបើកបរ
  - ជំរុញឱ្យឃុំយកចិត្តទុកដាក់ក្នុងការកសាង និងជួសជុលផ្លូវខូចខាតនេះតាមរយៈគម្រោងឃុំ ឬអត្តឃុំ
  - ធ្វើការជួសជុលកែសម្រួលផ្លូវក្រាលថ្មភ្នំ ឬគ្រួសក្រហមឱ្យទៅជាផ្លូវកៅស៊ូ ឬផ្លូវបេតុងអាមេ តាមរយៈ ការទំនាក់ទំនងទៅរដ្ឋបាលថ្នាក់ជាតិ ឬឥស្សរជនជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាល
  - ជំរុញការិយាល័យជំនាញលើកគម្រោងបោះបង្គោលបង្ហាញសញ្ញាចរាចរណ៍តាមផ្លូវកៅស៊ូក្នុងឃុំ។[32]

### ៣.១.២. ស្ថានភាពសង្គមកិច្ច

### ក. វិស័យអប់រំ

វិស័យអប់រំគឺជាតម្រូវការបន្ទាន់ និងចាំបាច់សម្រាប់អភិវឌ្ឍធនធានមនុស្សនៅក្នុងស្រុក ដើម្បីឱ្យស្របទៅនិងការរីកចម្រើននៃសង្គមជាតិ។ ស្ថានភាពការងារអប់រំសិក្សាធិការបានជំរុញឱ្យមានការអភិវឌ្ឍយ៉ាងច្រើនតែក៏នៅមិនទាន់បានល្អប្រសើរនៅឡើយទេ។ ស្រុកបាធាយមានវិទ្យាល័យ ៥, អនុវិទ្យាល័យ ៨ និងបឋមសិក្សា ៤៥ គ្រូសរុបចំនួនប្រមាណ ៥៨៥នាក់ ស្រីចំនួនប្រមាណ ៣០៣នាក់។

ការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើឱ្យវិស័យអប់រំ មានការប្រែប្រួលរីកចម្រើនល្អប្រសើរគួរឱ្យមានមោទនភាព តាមរយៈការគៀងគរជំនួយសប្បុរសជន, ស្នើសុំរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។

[32] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

៥ឆ្នាំកន្លងទៅស្រុកបានជំរុញឱ្យការសាងសង់អាគារសិក្សាថ្មីចំនួន ២១ខ្នង ស្មើនិង ១១៥បន្ទប់ ក្នុងនោះមានអាគារជំនួយរបស់ **សម្តេច ហ៊ុន សែន** ៨ខ្នង ស្មើនិង ៥២បន្ទប់, អាគារជំនួយរបស់អង្គការ School Aid Japan ៨ខ្នង ស្មើនិង ៣៧បន្ទប់, អាគារជំនួយរបស់អង្គការ Room To Read ចំនួន ៣ខ្នង ស្មើនិង ១៦បន្ទប់ និងអាគារជំនួយរបស់ក្រុមហ៊ុន GIC ជប៉ុនចំនួន ២ខ្នង ស្មើនិង ១០បន្ទប់។

គ្រោងសាងសង់ ១០ខ្នង និងអាគារការិយាល័យ ១ខ្នងទៀត នៅក្នុងអាណត្តិទី ២នេះ ដើម្បីបំពេញតម្រូវការរបស់មូលដ្ឋាន។ មត្តេយ្យរដ្ឋនៅ បឋមសិក្សាកើនដល់ ៣៦សាលា ស្មើនិង ៤៣ថ្នាក់រៀន សិស្សមត្តេយ្យចំនួន ១៥៣៦នាក់ ស្រីចំនួន ៨២០នាក់និងគ្រោងបង្កើតឱ្យបានដល់៤១សាលា ស្មើនិង ៤៩ ថ្នាក់រៀនក្នុងអាណត្តិទី ២ នេះមត្តេយ្យសហគមន៍មាន ចំនួន ១៨កន្លែង ស្មើនិង ២៣ថ្នាក់ កុមារកំពុងសិក្សាចំនួន ៧៣៧នាក់។ ជាងនេះទៅទៀត គ្រោងបង្កើតឱ្យបាន ៦ថ្នាក់ទៀត ដើម្បីផ្តល់លទ្ធភាពឱ្យកុមារអាយុ ៣-៥ឆ្នាំបានចូលរៀន និងអាចជួយសម្រាលបន្ទុករបស់មាតាបិតា កុមារមួយចំណែកផង។

កាត់បន្ថយអនក្ខរជនឱ្យនៅកម្រិតទាបបំផុត និងឈានទៅបំបាត់នៅពេលខាងមុខ តាមកិច្ចសហការជាមួយមន្ទីរអប់រំ អង្គការជាតិ អន្តរជាតិក្នុងការបង្កើតថ្នាក់អក្ខរកម្ម ព្រោះភាពអវិជ្ជានៃប្រជាពលរដ្ឋគឺជាឧបសគ្គនៃការអភិវឌ្ឍជីវភាពគ្រួសារ និងសង្គម។

- **បញ្ហាប្រឈម**
  - អត្រាបោះបង់ការសិក្សានៅតែមាន ហើយនៅមានអនក្ខរជនក្នុងភូមិ ឃុំ
  - ការត្រួតថ្នាក់ និងភាពនៅក្រៅសាលារបស់យុវជន
  - មធ្យមភាគនៃការប្រលងធ្លាក់ច្រើន (**សញ្ញាបត្រទុតិយភូមិ**)
  - កុមារតូចៗ នៅក្រៅសាលាច្រើន (**៣-៥ឆ្នាំ**)។
- **ដំណោះស្រាយ**
  - ចាក់វ៉ាក់សាំងការពារជំងឺកូវីដដល់សិស្សានុសិស្សឱ្យបានគ្រប់គ្នា
  - សង់អាគារ និងបណ្ណាល័យបន្ថែម
  - ជំរុញបង្កើតថ្នាក់មត្តេយ្យរដ្ឋ, មត្តេយ្យសហគមន៍ និងបើកថ្នាក់អក្ខរកម្ម
  - រៀបចំឱ្យមានក្រុមចុះអប់រំកុមារតាមផ្ទះ និងបំផុសអំពីផលប្រយោជន៍ការសិក្សាថ្នាក់មត្តេយ្យ
  - បង្កើនមជ្ឈមណ្ឌលសហគមន៍ និងបង្កើតមណ្ឌលអាននៅថ្នាក់ឃុំ
  - ពង្រឹងការសិក្សានៅតាមមធ្យមសិក្សា (**បង្រៀន និងការរៀន**)។

**ខ. វិស័យសុខាភិបាល (នៅឆ្នាំ២០២២រដ្ឋបាលស្រុកបាធាយបានជួបនូវវិបត្តិធ្ងន់ធ្ងរដោយប្រជាពលរដ្ឋចំនួន៨ឃុំបានឆ្លងកូវីដ១៩)**

ស្ថានភាពសុខភាពរបស់ពលរដ្ឋក្នុងស្រុកកំពុងបានល្អប្រសើរតាមបំណងប្រាថ្នា ដែលបានកំណត់នៅក្នុងគោលដៅសហស្សវត្សរ៍ និងទិសដៅក្នុងវិស័យ។ ពលរដ្ឋមានសុខភាពល្អ ការប្រកបមុខរបរចិញ្ចឹមជីវិតនិងបានប្រព្រឹត្តទៅជាប្រក្រតី ដោយមិនខាតបង់ពេលវេលា និងទ្រព្យសម្បត្តិ ហើយក៏ជៀសផុតពីភាពក្រីក្របានទៀតផង។

ស្រុកបាធាយមានការិយាល័យសុខាភិបាលប្រតិបត្តិ ១, មន្ទីរពេទ្យបង្អែក ១ និងមណ្ឌលសុខភាព ៧ ដែលមានបុគ្គលិកសរុបចំនួន ៨១នាក់ ក្នុងនោះវេជ្ជបណ្ឌិត ៨/១នាក់, ទន្តបណ្ឌិត ៤/១នាក់, ឱសថការីឧត្តមចំនួន៣/១នាក់, គណនេយ្យឧត្តមចំនួន ២នាក់, បរិញ្ញាបត្រឆ្មបចំនួន ៥/១នាក់, បរិញ្ញាបត្រគិលានុប្បដ្ឋាកចំនួន ២/២នាក់, គិលានុប្បដ្ឋាក មធ្យម ១៧នាក់ , គិលានុប្បដ្ឋាកបឋមចំនួន ១១នាក់ , ឆ្មបមធ្យមចំនួន ១០នាក់ , ឆ្មាំបឋមចំនួន ១៨នាក់ និងវិទ្យុសាស្ត្រចំនួន ១/១នាក់។

ចាប់ពីឆ្នាំ ២០១០ រហូតមកទល់បច្ចុប្បន្ន ការយល់ដឹងរបស់ប្រជាពលរដ្ឋមានការកើនឡើង ជាហេតុធ្វើឱ្យមានការងាយស្រួលច្រើនក្នុងការជំរុញអនុវត្តសកម្មភាពនានាក្នុងវិស័យសុខាភិបាល ជាពិសេសការសម្រាលកូនដោយឆ្មបបុរាណត្រូវបានលុបបំបាត់ចោលទាំងស្រុងដែលជា កត្តាមួយកាត់បន្ថយបានមួយកម្រិតថែមទៀតនូវអត្រាស្លាប់របស់កុមារនិងស្ត្រីជាមាតារបស់ទារក។ វិស័យនេះស្រុកកាន់តែមានលទ្ធភាពពង្រឹង និងថែទាំយ៉ាងយកចិត្តទុកដាក់ប្រកបដោយសុខុមាលភាពប្រជាជនថែមទៀតផង។ ស្រុកបានទទួលការគាំទ្រពីសាធារណរដ្ឋកូរ៉េជួយសាងសង់អគារមន្ទីរពេទ្យបង្អែកឡើងវិញ ១ខ្នង ២ជាន់ ស្មើនិង ៦០បន្ទប់ និងបំពាក់ឧបករណ៍ទំនើបៗសម្ភារៈបរិក្ខារពេទ្យគ្រប់គ្រាន់សម្រាប់ដំណើរការសកម្មភាពជាប្រយោជន៍ ក្នុងការពារសុខភាពប្រជាពលរដ្ឋក្នុងស្រុកជាពិសេសស្ត្រី និងកុមារ។

ថ្វីត្បិតវិស័យសុខាភិបាលមានភាពល្អប្រសើរច្រើន តែក៏នៅមានបញ្ហាប្រឈមខ្លះដែរគឺការមិនយកចិត្តទុកដាក់របស់ស្ត្រីដែលមានគភ៌ ក្នុងការមកពិនិត្យផ្ទៃពោះឱ្យបាន ៤ដងមុនពេលសម្រាល។ ម៉្យាងវិញទៀត ការផ្គត់ផ្គង់ថ្នាំពេទ្យសម្រាប់មណ្ឌលសុខភាព និងមន្ទីរពេទ្យ កន្លងទៅក៏នៅមានកម្រិត ពុំទាន់ធានាបានពេញលេញក្នុងការពិនិត្យព្យាបាលជម្ងឺជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះ ស្រុកក៏នៅមានប្រជាពលរដ្ឋងាយរងគ្រោះដែលត្រូវចាប់អារម្មណ៍ និងយកចិត្តទុកដាក់ដែរគឺ គ្រួសារដែលមានសមាជិកកើតជម្ងឺអេដស៍, កុមារកំព្រាអាយុក្រោម ១៨ឆ្នាំដែលឪពុកម្តាយស្លាប់ដោយសារមេរោគអេដស៍, ចាស់ជរាគ្មានទីពឹង និងជនពិការដែលមិនអាចរកប្រាក់ចំណូល។

ដើម្បីជួយសម្រាលបន្ទុកនៃការលំបាកនេះ ស្រុកមានគោលដៅសហការជាមួយអង្គការក្រៅរដ្ឋាភិបាល, សមាគម និងស្ថាប័នពាក់ព័ន្ធឱ្យជួយគាំទ្រ និងយកចិត្តទុកដាក់ដល់មុខសញ្ញាទាំងនេះ ជាពិសេសការអប់រំ និងផ្សព្វផ្សាយពីជម្ងឺឆ្លង និងផ្តល់ព័ត៌មានឱ្យបានទូលំទូលាយ ក្នុងការអប់រំ និងថែទាំសុខភាព។[33]

## គ. វិស័យអភិវឌ្ឍជនបទ

វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតែជាបញ្ហាប្រឈមនៅក្នុងស្រុកបាធាយ ដើម្បីជួយសម្រួលការលំបាករបស់ប្រជាពលរដ្ឋ ដើម្បីទទួលបាននូវទឹកស្អាត និងបង្គន់អនាម័យគ្រប់គ្រាន់។ ទោះបីជាច្រើនឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងជាមួយនិងការគាំទ្រពីដៃគូអភិវឌ្ឍនានា ដើម្បីកាត់បន្ថយភាព ក្រីក្ររបស់ប្រជាពលរដ្ឋជនបទ តាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដូចជា៖ ផ្លូវលំជនបទ, អណ្តូងទឹក ស្អាត, បង្គន់អនាម័យ, ស្រះទឹក, ការពង្រឹងសមត្ថភាពសហគមន៍ ក៏នៅតែមិនទាន់ឆ្លើយតបទៅតាមតម្រូវការចាំ បាច់ និងជាបន្ទាន់របស់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់នៅឡើយ។ សព្វថ្ងៃនេះប្រជាពលរដ្ឋនៅតាមភូមិ ឃុំមួយ ចំនួននៅតែប្រើប្រាស់ ប្រភពទឹកដែលមិនមានសុវត្ថិភាពដូចជា៖ ទឹកស្រះ ស្ទឹង បឹង និងទន្លេជាដើម ដែលបង្កឱ្យមានផលប៉ះពាល់ដល់សរីរាង្គ អសរីរាង្គ និងមេរោគដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពនិងសេដ្ឋកិច្ច។

ផ្អែកតាមរបាយការណ៍នាយកដ្ឋានទឹកស្អាតជនបទ នៃក្រសួងអភិវឌ្ឍជនបទ កាលពីឆ្នាំ ២០១៤ បានបង្ហាញឱ្យឃើញថា វិសាលភាពសេវាផ្គត់ផ្គង់ទឹកស្អាតទើបតែទទួលបាន ៤៥%ប៉ុណ្ណោះនៅទូទាំងប្រទេស។ ដោយឡែកស្រុកបាធាយស្ថិតនៅក្រោមតួលេខទូទាំងប្រទេសនេះទៀត។គោលដៅអភិវឌ្ឍសហវត្សន៍របស់រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថា នៅឆ្នាំ ២០២០ឬ ២០២៥ ប្រជាពលរដ្ឋរស់នៅតាមទីជនបទប្រមាណ ៥៥% និង ទទួលបាននូវការប្រើប្រាស់ទឹកស្អាត ហើយចំនួន ៣៧ % ទៀតនិងទទួលបានបង្គន់អនាម័យប្រើប្រាស់។

- **បញ្ហាប្រឈម**
  - ខ្វះអនាម័យ (មិនមានទឹកស្អាត និងខ្វះបង្គន់អនាម័យ)
  - ឆ្លងជំងឺកូវីដ១៩
  - ខ្វះថវិកាផ្គត់ផ្គង់សម្រាប់អ្នកធ្វើចត្តាឡីស័ក
  - ធ្វើឱ្យសេដ្ឋកិច្ចប្រជាពលរដ្ឋធ្លាក់ចុះជាខ្លាំង។
- **ដំណោះស្រាយ**
  - បណ្តុះបណ្តាលពីគម្រោងសហគមន៍ និងការលើកកម្ពស់អនាម័យល្អ
  - ផ្សព្វផ្សាយពីគម្រោងសហគមន៍ និងការលើកកម្ពស់ប្រតិបត្តិអនាម័យល្អ

[33] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

- ចុះជំរុញ និងផ្ដល់បច្ចេកទេសក្នុងការកសាងបង្គន់អនាម័យតាមគ្រួសារ
- ចាត់វិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩។

## ឃ. វិស័យយេនឌ័រ

ប្រជាពលរដ្ឋបានស្វែងយល់អំពីសមភាពរវាងបុរស និងស្ត្រី សមភាពយេនឌ័រត្រូវបានប្រជាពលរដ្ឋ និងមហាជនទូទៅចូលរួមលើកកម្ពស់ជាបន្តបន្ទាប់។ ក៏ប៉ុន្តែនៅមានភាពអសកម្មខ្លះដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្មើភាពទាំងនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងការរស់នៅរបស់ស្ត្រី ជាពិសេសជនងាយរងគ្រោះ ដូចជាៈ កុមារីត្រូវបោះបង់ចោលការសិក្សាមុនការបញ្ចប់រៀនអក្សរចំណេះទូទៅក្រោមថ្នាក់ទី ៩ (ដោយអូសទាញកុមារីឱ្យជួយធ្វើការ និងស្វែងរកកម្រៃផ្គត់ផ្គង់ជីវភាពគ្រួសារ)។

ការផ្សព្វផ្សាយស្វែងយល់អំពីសមភាព និងសមធម៌កាន់តែត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ តាមរយៈការប្រជុំផ្សព្វផ្សាយ, សិក្ខាសាលា, ផ្ដល់ឱកាសការងារ និងការផ្ដល់ឱកាសក្នុងការចូលរួមមតិយោបល់ដោយមិនមានការរើសអើង។ ស្ត្រីក៏នៅតែជួបបញ្ហាដោយអន្លើៗ ផងដែរ ព្រោះថាស្ត្រីគឺជាមេផ្ទះដែលទទួល រ៉ាប់រងកិច្ចការគ្រួសារច្រើនជាងបុរសជាហេតុនាំឱ្យស្ត្រីមិនសូវមានឱកាសក្នុងការបង្កើនសមត្ថភាពរបស់ខ្លួនបានដូចបុរសម៉្យាង ដោយសារជីវភាពគ្រួសារមិនទាន់បានល្អប្រសើរ ទើបស្ត្រីភាគច្រើនពុំសូវមានឆន្ទះក្នុងការចូលរួម កម្មវិធីផ្សេងៗ ដែលជាការស្វែងយល់ ឬបង្កើនចំណេះដឹង,ចំណេះធ្វើសម្រាប់បម្រើឱ្យសង្គមគ្រួសារ និងសង្គមជាតិ បានពេញលេញនៅឡើយ។

ចំណាកស្រុកក៏ជួបបញ្ហាប្រឈមរបស់ស្ត្រីផងដែរតួលេខឆ្នាំ២០១៧ ដល់ ឆ្នាំ២០២១ ប្រជាពលរដ្ឋចំណាកស្រុកក្រៅ ប្រទេសចំនួនប្រមាណ ២៧៥៤នាក់ ស្មើនិង៣.៤% ក្នុងនោះស្ត្រី ៩៩៩នាក់ ស្មើនិង ២.៤%។ មួយវិញទៀត ស្ត្រីជាមេគ្រួសារ ចំនួន១៥.១% ជាគ្រួសារក្រីក្រ ហើយមានកូនតូចៗ ក្រោមអាយុ ៥ឆ្នាំនៅក្នុងបន្ទុក គ្រួសារទាំងនោះត្រូវជួបការ លំបាកលើជីវភាពប្រចាំថ្ងៃ ក្នុងការរកប្រាក់ចំណូលចិញ្ចឹមជីវិត និងផ្គត់ផ្គង់ជីវភាពគ្រួសារដែលបណ្ដាលឱ្យជួបស្ថាន ភាពកង្វះអាហារូបត្ថម្ភដល់កុមារក្នុងបន្ទុក។[34]

- **បញ្ហាប្រឈម**
  - ស្ត្រីខ្វះការចូលរួមក្នុងសង្គម, ខ្វះភាពអង់អាច និងគ្មានមុខរបរជាក់លាក់
  - ស្ត្រីខ្វះការយល់ដឹងពីជំនាញបច្ចេកទេស ការអប់រំក្នុងចំណោមស្ត្រីមានកម្រិតទាប។
- **ដំណោះស្រាយ**
  - ផ្សព្វផ្សាយជំរុញស្ត្រីឱ្យចូលរួមលើកិច្ចអភិវឌ្ឍក្នុងសហគមមន៍ និងសង្គមជាតិ

[34] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

- បង្កើនសមត្ថភាពស្ត្រីដោយបណ្តុះបណ្តាលជំនាញ, បង្កើនមុខរបរ និងផ្តល់មុខជំនាញ
- បង្កើនភាពអង់អាចដល់ស្ត្រីធ្វើសេចក្តីសម្រេចចិត្តឱ្យមានតួនាទី និងភារកិច្ចក្នុងការងារសង្គម។

### ៣.១.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

#### ក. ការប្រើប្រាស់ដីធ្លី

ការប្រើប្រាស់ដីទូទៅកត់សំគាល់ឃើញថា ដីធ្លីវាបានក្លាយជាដីកសិកម្មស្ទើរទាំងអស់ ដូចជា៖ ដីបឹងបួរ គោករាក់, ដីព្រៃទឹកលិចនៅរដូវវស្សា ប្រជាពលរដ្ឋបានប្រែក្លាយដី ទាំងនោះទៅជាដីធ្វើស្រូវ រដូវប្រាំង និងដាំដំណាំកសិផលផ្សេងៗដូចជា៖ឈូកជាដើមដោយសារកំណើនប្រជាពលរដ្ឋពីមួយឆ្នាំទៅមួយឆ្នាំកើនឡើង។

- **បញ្ហាប្រឈម**
  - មិនទាន់កំណត់ ( ប្លង់មេ ) ដីគ្រប់គ្រងដីសាធារណៈច្បាស់លាស់
  - ទំនាស់ដីធ្លីដណ្តើមសិទ្ធិកាន់កាប់
  - ការកាប់ទន្រ្ទានដីព្រៃទឹកលិចធ្វើស្រែប្រាំង និងកាប់គាស់ទន្រ្ទានដីសាធារណៈធ្វើជាកម្មសិទ្ធិ។
- **ដំណោះស្រាយ**
  - ជំរុញការិយាល័យភូមិបាលកសាងប្លង់មេទីប្រជុំជន
  - ទប់ស្កាត់ការទន្រ្ទានដីលិចទឹក និងផ្សព្វផ្សាយច្បាប់បរិស្ថាន, ច្បាប់ភូមិបាល, ច្បាប់ជលផល។

#### ខ. ការគ្រប់គ្រងដីធ្លី

លក្ខណៈភូមិសាស្ត្រ និងសណ្ឋានដីផ្សេងៗគ្នា ជាពិសេសសក្តានុពលធនធានដែលអាចឆ្លុះបញ្ចាំងពីរបៀប របបរស់នៅ និងកម្រិតជីវភាពប្រជាពលរដ្ឋមិនស្មើគ្នាឡើយ។ សណ្ឋានផ្ទៃដីចែកចេញជាវាលទំនាប ក្នុងនោះជាផ្ទៃ ដីផលិតស្រូវវស្សា និងស្រូវប្រាំង។ តំបន់កូនភ្នំតូចៗ ដែលមាននៅក្នុងឃុំតាំងក្រាំង, ជាលា, បាធាយ និងឃុំគ្រប់ និងដីទីទួលមាននៅក្នុងឃុំផ្អាវ ឃុំជើងព្រៃ និងឃុំទំនប់។

ផ្ទៃដីវាលទំនាបដែលផលិតស្រូវប្រាំង និងវស្សាមួយចំនួនជារៀងរាល់ឆ្នាំតែងតែទទួលរងនូវឥទ្ធិពលទឹកទន្លេមេគង្គ និងទន្លេសាបឡើងលិចជាប្រចាំ ដែលកន្លងទៅបានពិនិត្យឃើញតាមបណ្តាឆ្នាំខ្លះគឺមានអំណោយផលពីទឹកទន្លេ ទាំង ២ខាងលើ ប៉ុន្តែឆ្នាំខ្លះក៏ទទួលរងគ្រោះធម្មជាតិ ដោយទឹកមានកម្រិតទាបមិនអាចឱ្យកសិករអូសទាញទឹកនោះ មកបង្កបង្កើនផលបាន តែក៏មានឆ្នាំខ្លះត្រូវលិចលង់ ដោយទឹកជំនន់នៃទន្លេនេះដែរ ឃុំដែលរងគ្រោះញឹកញាប់គឺឃុំសំបួរ, តាំងក្រាំង, ជាលា, ច្បារអំពៅ, បាធាយ, មេព្រីង, ជើងព្រៃ, តាំងក្រសាំង និងឃុំគ្រប់ ដោយឃុំទាំង ៩ នេះជាតំបន់ទំនាប។

❖ បញ្ហាប្រឈម

➢ ប្រជាពលរដ្ឋមានកំណើនឡើង រីឯផ្ទៃដីបង្កបង្កើនផលនៅដដែល

➢ ជួបប្រទះគ្រោះធម្មជាតិញឹកញាប់។

❖ ដំណោះស្រាយ

➢ កែទម្រង់ការប្រើប្រាស់ដីធ្លីតាមលក្ខណៈបច្ចេកទេស ដើម្បីបង្កើនទិន្នផលស្រូវ

➢ ត្រៀមបង្ការឱ្យបានមុននូវការការពារ និងផ្គត់ផ្គង់ទឹក។[35]

**គ. វិស័យបរិស្ថាន**

ការបំពុលបរិស្ថានដែលបង្កឡើងដោយការផលិតថ្មសំណង់ ដែលមានទីតាំងនៅឃុំតាំងក្រាំងត្រូវបានកាត់បន្ថយផលប៉ះពាល់ ដោយក្រុមហ៊ុននេះដល់អាណត្តិផុតកិច្ចសន្យា ឬកន្លងទៅមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋរស់នៅជុំវិញនោះ។បញ្ហាកាកសំណល់រឹង និងរាវចោទខ្លាំងនៅតាមបណ្តាឃុំ ដូចជា៖ ឃុំផ្អាវ ឃុំបាធាយ និង ឃុំតាំងក្រាំង ដែលមានទីតាំងផ្សារលក់ទំនិញ។ កាកសំណល់រាវត្រូវបានបង្ហូរចេញពីលំនៅដ្ឋានក្នុងទីប្រជុំជន, ផ្សារ ហើយសារធាតុទាំងនោះនិងអាចជ្រៀតចូលក្នុងដី ហើយអាចប៉ះពាល់ប្រភពទឹកក្នុងដី។

កាកសំណល់រឹងត្រូវបាន ប្រជាពលរដ្ឋយកមកចាក់ចោលតាមបណ្តាយផ្លូវជាតិដោយកំបាំងមុខ។ ការប្រើប្រាស់ថ្នាំពុលកសិកម្មគឺមានទំហំធំ ជាទូទៅក្នុងស្រុក ពិសេសនៅឃុំបាធាយ ឃុំជាលា ឃុំសំបូរ ឃុំតាំងក្រាំង ឃុំមេព្រីង និងឃុំជើងព្រៃ កត្តាទាំងនេះ បានធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស, ជីវិតសត្វ, ជម្រកត្រី និងជីវៈចម្រុះសំខាន់ៗទៀតនៅក្នុងបឹងបួរត្រពាំង។

❖ បញ្ហាប្រឈម

➢ ពុំមានវិធានការគ្រប់គ្រងកាកសំណល់រឹង រាវ ធូលីហុយ និងផ្សែង

➢ ការប្រើប្រាស់ថ្នាំពុល ខ្វះបច្ចេកទេស និងការខូចខាតដោយគ្រោះធម្មជាតិ

➢ ខ្វះការយកចិត្តទុកដាក់លើកាកសំណល់លាមកមនុស្ស និងសត្វ។

❖ ដំណោះស្រាយ

➢ ផ្សព្វផ្សាយច្បាប់បរិស្ថាន និងមានវិធានការចំពោះបាតុភាពល្មើសជាក់ស្តែង

➢ អប់រំការប្រើប្រាស់ថ្នាំពុល និងផលប៉ះពាល់

➢ បង្កើតទីតាំងស្តុកសម្រាម ធុងសម្រាម និងជំរុញការផ្តល់សេវាប្រមូលសម្រាម។

[35] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

**ឃ. វិស័យជលផល**

ស្រុកបាធាយមានឡូត៍នេសាទចំនួន ២ គឺឡូត៍លេខ ៤ និង ៥ ។ ចំពោះឡូត៍លេខ ៤ ត្រូវរដ្ឋកាត់ឱ្យប្រជាពលរដ្ឋប្រកបមុខរបរ និងឡូត៍លេខ ៥ ត្រូវកាត់ ៥០% ជូនប្រជាពលរដ្ឋដែរ។ ផ្ទៃបឹងឡូត៍នេសាទដែលរដ្ឋប្រគល់ ជូនសហគមន៍ ដើម្បីទទួលផលគឺជាតំបន់ជម្រកត្រីធម្មជាតិ ក៏ប៉ុន្តែមាត់បឹងបួដែលព្រៃលិចទឹកសម្រាប់ជាទីជម្រកមច្ឆាត្រូវប្រជាពលរដ្ឋកាប់ទន្ទ្រានទៅជាផ្ទៃដីបង្កបង្កើនផលស្រូវ ដើម្បីជួយបំពេញបន្ថែមលើជីវភាពរបស់ពួកគាត់។ ជាមួយនេះដែរក៏មានការនេសាទត្រីដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់ ដូចជា៖ ស្បៃមុងប្រើក្នុងពេល ហាមឃាត់នេសាទ និងមានការប្រើប្រាស់ឧបករណ៍ឆក់ដែលធ្វើឱ្យបាត់បង់ពូជមច្ឆាជាតិ ជាមួយគ្នានេះក៏មានការ រងនូវជាតិថ្នាំពុលកសិកម្មផងដែរ។

❖ **បញ្ហាប្រឈម**

- បឹង ត្រពាំង រីងរាក់ និងការកាប់រានព្រៃលិចទឹកដែលជាជម្រកត្រី
- ការនេសាទប្រើឧបករណ៍ខុសច្បាប់នៅតែមាន និងការប្រើប្រាស់ថ្នាំពុលកសិកម្មខ្វះបច្ចេកទេស។

❖ **ដំណោះស្រាយ**

- បង្កើនសកម្មភាពទប់ស្កាត់បទល្មើសនេសាទ រួមទាំងការដាក់សម្រះក្នុងបឹង
- លើកទំនប់ឱ្យខ្ពស់ និងស្តារបឹងដែលរាក់
- អប់រំកាត់បន្ថយការប្រើប្រាស់ថ្នាំពុល និងជំរុញការផលិតជីធម្មជាតិ
- ជំរុញការទទួលខុសត្រូវរបស់មន្ត្រីជលផល, ការចូលរួមរបស់មូលដ្ឋានក្នុងកិច្ចការពារ។

**ង. វិស័យព្រៃឈើ**

ដោយស្រុកបាធាយជាតំបន់វាលទំនាបគ្របដណ្តប់ដោយទឹកទន្លេមេគង្គនៅរដូវវស្សា ហើយមានព្រែក បឹង បួរផង នោះគឺជាតំបន់ដែលមានព្រៃលិចទឹកពាក់កណ្តាលនៃផ្ទៃដីសរុប ដែលជាជម្រកត្រីពងនារដូវវស្សា និងសត្វស្លាបនានា ព្រមទាំងអាចផ្តល់ជាអុសសម្រាប់ចំអិនអាហារបានមួយចំណែក ហើយពុំមានព្រៃស្រោងធំៗទេ គឺមានព្រៃតូចៗប៉ុណ្ណោះ។ បច្ចុប្បន្ននេះព្រៃលិចទឹកទាំងនោះនៅសល់តែប្រមាណ ១,០% ដោយប្រជាពលរដ្ឋបានកាប់ រានធ្វើស្រែប្រាំងស្ទើរអស់។

### ៣.១.៤. ស្ថានភាពគ្រប់គ្រងរដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

**ក. វិស័យរដ្ឋបាលដែនដី**

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលវែងគឺកសាងសង្គមកម្ពុជាមួយដែលមានសន្តិភាព,ស្ថេរភាពនយោបាយ, សន្តិសុខសណ្តាប់ធ្នាប់សង្គម, កំណើនសេដ្ឋកិច្ចរយៈពេលវែង, ការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌, ការកែលម្អជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ការពារបរិស្ថាន, ការលើកស្ទួយវប្បធម៌ និងអត្តសញ្ញាណជាតិជាមួយនិងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងគោរព សិទ្ធិ និងសេចក្តីថ្លៃថ្នូរ, មានកោសិកាផ្សារភ្ជាប់គ្នា (មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ, មានជីវភាពសមរម្យ និងការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ និងសង្គមគ្រួសារ)។ ដើម្បីចូល រួមសម្រេចឱ្យបានចក្ខុវិស័យនេះ រដ្ឋបាលដែនដីនៅថ្នាក់ក្រោមជាតិ ដែលជារដ្ឋបាលសាធារណៈត្រូវខិតខំអនុវត្តឱ្យបានសកម្មនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលជាឧបករណ៍នយោបាយប្រកបដោយប្រសិទ្ធិភាពមួយ។

ក្នុងការឈានទៅសម្រេចបាននូវ ចក្ខុវិស័យខាងលើនេះ ជាពិសេសខ្លឹមសារនៃអភិបាលកិច្ចល្អដែលជាស្នូលនៃ យុទ្ធសាស្ត្រចតុកោណ ហើយដែលត្រូវបានរាជរដ្ឋាភិបាលធ្វើការកែទម្រង់បន្ថែមទៀតដោយឥតរាថយព្រោះថា អភិបាលកិច្ចល្អនៅតែជាស្នូលនៃយុត្តិធម៌សង្គមនិងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយចីរភាព និងសមធម៌។ សំខាន់ជាងនេះទៅទៀត គឺធ្វើឱ្យសកម្មភាពទាំងឡាយ បានបម្រើផលប្រយោជន៍ប្រជាជនមូលដ្ឋានកាន់តែច្រើន ឡើងនិងបង្កិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋមានតារាងកំណត់តម្លៃសេវាច្បាស់លាស់។ រដ្ឋបាលសាធារណៈនិងត្រូវមានភាពឆ្លើយតបប្រកបដោយប្រសិទ្ធិភាព និងជំនឿទុកចិត្ត ហើយលើកកម្ពស់វប្បធម៌នៃការផ្តល់សេវាសាធារណៈ ប្រកបដោយឆន្ទៈ, ម្ចាស់ការភក្តីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការ ដើម្បីប្រែក្លាយ រដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាសាធារណៈកាន់តែល្អប្រសើរឡើង។

ស្រុកបាធាយមាន ១២ឃុំ និង ៨០ភូមិ។ រដ្ឋបាលស្រុកមានអង្គក្រុមប្រឹក្សាមានសមាសភាព ២១នាក់ស្រី ៣នាក់ គណៈអភិបាល៥នាក់ស្រី ១នាក់និងគណៈកម្មាធិការមាន៣ គឺគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ,គណៈកម្មាធិការលទ្ធកម្ម និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ។ រដ្ឋបាលស្រុកមាន៖ នាយករដ្ឋបាល១, នាយករង២នាក់ ការិយាល័យចំនួន១៣ មន្ត្រីសរុបចំនួន៨៦នាក់ ស្រី២២ និងបានធ្វើសមាហរណកម្មឱ្យក្រុមប្រឹក្សាស្រុកដែលជារដ្ឋបាលថ្នាក់ក្រោមជាតិកាលពីថ្ងៃទី៣១ខែមករាឆ្នាំ២០២០។

❖ **បញ្ហាប្រឈម**

- ការយល់ដឹងរបស់មន្ត្រីរាជការនៅមានកម្រិត មិនទាន់មានសមត្ថភាពពេញលេញក្នុងការប្រតិបត្តិ
- បរិក្ខារ ឧបករណ៍ សម្ភារៈបច្ចេកទេសមិនគ្រប់តាមតម្រូវការ (**ព័ត៌មានវិទ្យា**)
- អគារសាលាឃុំស្តង់ដារក្រសួងមហាផ្ទៃមិនទាន់គ្រប់ឃុំនៅឡើយ (**ខ្វះចំនួន ៦**)
- ការផ្តល់ព័ត៌មានពីមូលដ្ឋានភូមិ ឃុំមិនច្បាស់លាស់ និងមិនទាន់សភាពការណ៍
- ការគ្រប់គ្រងទិន្នន័យនៅតាមមូលដ្ឋានឃុំ មិនទាន់សុក្រិតទៅនិងស្ថានភាពពិត

- ប្រជាពលរដ្ឋមិនយកចិត្តទុកដាក់លើការងារអត្រានុកូលដ្ឋាន ជាហេតុនាំឱ្យប្រជាជនមួយចំនួនមិនទាន់មានអត្រានុកូលដ្ឋានកំណើត និងប្រជាជនភាគច្រើនមានទិន្នន័យអត្រានុកូលដ្ឋានខុសពីស្ថានភាពពិតរបស់សាមីខ្លួន
- ប្រជាពលរដ្ឋដែលមានកូនកើតក្នុងរយៈពេល ៣០ថ្ងៃ មិនយកចិត្តទុកដាក់ក្នុងការចុះសំបុត្រកំណើតទុក រហូតដល់កូនជិតគ្រប់អាយុ ៦ឆ្នាំចូលរៀន ទើបទៅរកធ្វើសំបុត្រកំណើត
- មានការលួចកែតម្រូវអត្រានុកូលដ្ឋានរបស់ឃុំតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដែលគ្មានទិន្នន័យក្នុងគល់បញ្ជី ជាហេតុធ្វើឱ្យសាមីខ្លួនមិនអាចទទួលបានការធ្វើសេចក្តីចម្លងពីសាលាស្រុក ព្រោះគ្មានគល់បញ្ជី។

❖ ដំណោះស្រាយ

- បង្កើនសមត្ថភាពដល់មន្ត្រីរាជការ, ខិតខំច្នៃប្រឌិតឱ្យមានឧបករណ៍ព័ត៌មានវិទ្យា
- យកចិត្តទុកដាក់ស្នើសុំការកសាងអាគាររដ្ឋបាលឃុំ និងជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន
- បន្តពង្រឹងរបៀបរបបរាយការណ៍ ដើម្បីផ្តល់ព័ត៌មានទៅមកទាន់ពេល និងច្បាស់លាស់
- ពង្រឹងលើការគ្រប់គ្រងទិន្នន័យមូលដ្ឋាន ដើម្បីងាយស្រួលក្នុងការអភិវឌ្ឍ។[36]

### ខ. រដ្ឋបាលសាលាស្រុក

នៅក្នុងរដ្ឋបាលស្រុកបានធ្វើការបែងចែកភារកិច្ចតាមរចនាសម្ព័ន្ធ៖ គណៈអភិបាល ៥រូប, នាយក និងនាយករងរដ្ឋបាល ២រូប, ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ៧រូប, ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ១រូប, ការិយាល័យអន្តរវិស័យ ១រូប និងអង្គភាពលទ្ធកម្ម ២រូប ដែលបានបែងចែកភារៈកិច្ចអនុវត្តជាប្រក្រតីលើការទទួលខុសត្រូវ ដើម្បីបម្រើរាជរដ្ឋាភិបាល និងផ្តល់សេវាជូនប្រជាពលរដ្ឋ។

❖ បញ្ហាប្រឈម

- ការផ្តល់របាយការណ៍ពីឃុំ និងការិយាល័យជំនាញមិនទាន់ពេលបូកសរុប
- វត្តមានមន្ត្រីមិនពេញលេញក្នុងសប្តាហ៍ (ប្រចាំថ្ងៃ), ខ្វះសម្ភារៈ និងឧបករណ៍ការិយាល័យ
- ការគ្រប់គ្រងទិន្នន័យមូលដ្ឋានមិនទាន់បានច្បាស់លាស់
- អត្រានុកូលដ្ឋានខុសគ្នា (សៀវភៅគ្រួសារ, បញ្ជាក់ការសិក្សា និងអត្រានុកូលដ្ឋាន) នាំឱ្យលំបាកក្នុងការធ្វើច្បាប់ចម្លងជូនប្រជាពលរដ្ឋ។

---
[36] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

❖ **ដំណោះស្រាយ**

- ពង្រឹងរបបរាយការណ៍របស់មូលដ្ឋានឃុំប្រចាំខែ
- បង្កើនការទទួលខុសត្រូវរបស់មន្ត្រីសាលាស្រុកក្នុងការផ្ដល់សេវារដ្ឋបាល
- ជំរឿនស្ថិតិគ្រប់ផ្នែកប្រចាំឆមាស និងប្រចាំឆ្នាំ
- ជំរុញការចុះបញ្ជីអត្រានុកូលដ្ឋានឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាត្រូវចុះ
- ពង្រឹងការធ្វើច្បាប់ចម្លងឱ្យបានស្របនិងសៀវភៅគល់បញ្ជីតម្កល់។

**គ. អភិបាលកិច្ចល្អ**

អភិបាលកិច្ចល្អដែលស្ថិតនៅចំណុចស្នូល នៃយុទ្ធសាស្ត្រចតុកោណដោយកំណត់យកការចូលរួមជាសាធារណៈប្រកបដោយសមធម៌ និងយុត្តិធម៌នៅក្នុងបញ្ហាទាំងអស់ តាមរយៈការពិគ្រោះយោបល់, របៀបរបបការងារដែលមាន លក្ខណៈប្រជាធិបតេយ្យដែលធានាថាឆន្ទៈ និងការជ្រើសរើសរបស់មនុស្សភាគច្រើនត្រូវបានអនុម័តយក និងអនុវត្ត ស្របពេលជាមួយគ្នាដោយធានាឱ្យមានការការពារសិទ្ធិនិងសុខុមាលភាពរបស់មនុស្ស។ ស្ថេរភាពនយោបាយ, សន្តិសុខសុវត្ថិភាពផ្ទៃក្នុង, ការប្រកាន់ខ្ជាប់នូវការគ្រប់គ្រងដោយច្បាប់ និងតម្លាភាពភាពអាចដឹងមុនបាន និងគណនេយ្យភាពនៃស្ថាប័នសាធារណៈ គឺមានសារៈសំខាន់សម្រាប់ការរីកចម្រើនជាប្រក្រតីនៃផ្នែកសេដ្ឋកិច្ចនិងធនធានមនុស្សនិងកិច្ចការពារផលប្រយោជន៍សាធារណៈឱ្យរួចផុតពីការបំផ្លិចបំផ្លាញដោយកម្លាំងដែលប៉ងធ្វើការរំខាន។

❖ **បញ្ហាប្រឈម**

- សមត្ថភាពមន្ត្រីនៅមានកម្រិត, ខ្វះឧបករណ៍ និងសម្ភារៈ, ខ្វះថវិកាចំណាយរដ្ឋបាលប្រចាំថ្ងៃ
- ការឆ្លើយតបនិងតម្រូវការរបស់ប្រជាពលរដ្ឋមិនទាន់បានល្អ
- ខ្វះការចូលរួមរបស់ប្រជាពលរដ្ឋ និងសហគមន៍។

❖ **ដំណោះស្រាយ**

- វគ្គបណ្ដុះបណ្ដាលសមត្ថភាព និងជំរុញមន្ត្រីបង្កើនចំណេះដឹងដោយខ្លួនឯង តាមសាលាឯកជន
- យកចិត្តទុកដាក់បង្កើនសម្ភារៈ បរិក្ខារសម្រាប់បំពេញកិច្ចការរដ្ឋបាល
- បន្តពង្រឹងការឆ្លើយតបជូនប្រជាពលរដ្ឋឱ្យទាន់ពេលវេលា
- បំផុសចលនាចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសង្គម (**ចលនាប្រជាការពារ**)។[37]

---

[37] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

## ឃ. វិស័យសន្តិសុខ សណ្តាប់ធ្នាប់សង្គម

សន្តិសុខនៅស្រុកបាធាយបច្ចុប្បន្នកំពុងត្រូវបានពង្រឹង និងចាត់វិធានការទប់ស្កាត់ និងបង្ក្រាបរាល់ករណីកើតឡើងដោយសមត្ថកិច្ចជំនាញ, បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់រាល់សកម្មភាពក្នុងវិស័យនេះឱ្យល្អប្រសើរ ដើម្បីទំនុកទុកចិត្តលើប្រជាពលរដ្ឋភ្ញៀវទេសចរជាតិ អន្តរជាតិ, អ្នកនយោបាយជាតិ អន្តរជាតិដែលបានឆ្លងកាត់ ឬស្នាក់នៅក្នុងភូមិសាស្ត្រស្រុកកន្លងមក។ ជាងនេះទៅទៀតយកចិត្តទុកដាក់ពីសណ្តាប់ធ្នាប់ នៅតាមដងផ្លូវជាតិ, ផ្លូវលំ ភូមិ ឃុំ ដើម្បីរក្សាសុវត្ថិភាព និងអន្តរាគមន៍ចំពោះការកើតឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដែលអាច មានលទ្ធភាពសង្គ្រោះបន្ទាន់ បានចងក្រងឯកសារប្រសិទ្ធិភាពការពារជនរងគ្រោះបានទាន់ហេតុការណ៍,យកចិត្តទុកដាក់ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ជើងគោក ដើម្បីកាត់បន្ថយលើករណី គ្រោះថ្នាក់ចរាចរណ៍ ដែលអាចប៉ះពាល់ដល់ពិការភាព និងអាយុជីវិតប្រជាពលរដ្ឋ។ ទន្ទឹមនិងនេះ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលចាំបាច់ ត្រូវបន្តការចាប់អារម្មណ៍និងយកចិត្តទុកដាក់កែលម្អឱ្យបានល្អប្រសើរ ថែមទៀត រួមមាន៖ បញ្ហាគ្រោះថ្នាក់ចរាចរ, អំពើហឹង្សា, គ្រឿងញៀន និងបទល្មើសនេសាទ។

❖ បញ្ហាប្រឈម

- ការបញ្ជាយានយន្តហួសល្បឿនកំណត់
- យកចិត្តទុកដាក់ការអនុវត្តច្បាប់ចរាចរណ៍ជើងគោកមិនទាន់បានល្អ
- ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- បទល្មើសនេសាទនៅតែកើតមានឡើង។

❖ ដំណោះស្រាយ

- បង្កើនការត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ជើងគោក
- បន្តផ្សព្វផ្សាយច្បាប់ចរាចរណ៍ជើងគោកថ្មី
- ស្វែងរកមុខសញ្ញាចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- បង្កើនវិធានការណ៍ទប់ស្កាត់បទល្មើសនេសាទ។[38]

## ង. វិស័យភូមិឃុំមានសុវត្ថិភាព

ជាមួយគ្នានេះដែរ ការចាត់តាំងអនុវត្តគោលនយោបាយភូមិឃុំឱ្យមានសុវត្ថិភាព នៅតែជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត ឱ្យមានការរីកចម្រើនជាលំដាប់។

[38] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

ជាពិសេសបង្កើនសេចក្តីសុខសុវត្ថិភាព កាត់បន្ថយគ្រោះថ្នាក់ និងគ្រោះមហន្តរាយដល់ជនគ្រប់រូបនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា តាមរយៈការតស៊ូលុបបំបាត់បទល្មើស គ្រប់ប្រភេទក្នុងមូលដ្ឋានភូមិ ឃុំដែលក្នុងផែនការណែនាំ **ថ្មី លេខ ០២២ ផ.ក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១២** ត្រូវបានបង្កើនលក្ខណៈសម្បត្តិនៃភូមិ ឃុំមានសុវត្ថិភាព កើនដល់ ៩ចំណុច រួមមាន៖

១. គ្មានសកម្មភាពចោរលួចឆក់ប្លន់គ្រប់ប្រភេទ

២. គ្មានការដាំដុះ ការផលិត ការចរាចរណ៍ ការជួញដូរ ការចែកចាយនិងប្រើប្រាស់គ្រឿងញៀន

៣. គ្មានអំពើអាណាចារ្យការជួញដូរស្ត្រី និងកុមារ និងអំពើហឹង្សាក្នុងគ្រួសារ

៤. គ្មានក្រុមក្មេងទំនើង

៥. គ្មានល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ

៦. គ្មានគ្រោះថ្នាក់ចរាចរណ៍

៧. គ្មានគ្រោះថ្នាក់ដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៨. មានវិធានការណ៍ទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធិភាព

៩. គ្មានការត្រួតពិនិត្យខុសច្បាប់។

- **បញ្ហាប្រឈម**
  - កម្លាំងសមត្ថកិច្ចមិនគ្រប់គ្រាន់តាមភូមិសាស្ត្រជាក់ស្តែង
  - ទីតាំងប៉ុស្តិ៍រដ្ឋបាលឃុំពុំសមស្របនិងកន្លែងធ្វើការ។
- **ដំណោះស្រាយ**
  - ពង្រឹងកម្លាំងសន្តិសុខភូមិ និងកម្លាំងប្រជាការពារ ដើម្បីជួយការងារសន្តិសុខជាមួយសមត្ថកិច្ច
  - ជំរុញ និងរកលទ្ធភាពកសាងអាគាររដ្ឋបាលរបស់នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ។

## ៣.២. សង្ខេបប្រភពមូលនិធិឆ្នាំ ២០២១

ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុករួមទាំង គណៈកម្មាធិការកសាងផែនការបានកំណត់នូវដំណោះស្រាយតាមតម្រូវការចាំបាច់ និងអាទិភាពនៃគម្រោងស្នើឡើង ដើម្បីឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ, ធានាសន្តិសុខស្បៀង, បង្កើនប្រាក់ចំណូល ឆ្ពោះទៅកាត់បន្ថយជាបណ្តើរៗនៃភាពក្រីក្រ។

ក្រោយពីសិក្ខាសាលាសមារណកម្មកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល នៅថ្នាក់ស្រុក គម្រោងវិនិយោគរបស់ស្រុកមិនមានការសន្យាគាំទ្រទេ ដោយយោងលើការវិភាគស្ថានភាពតម្រូវការក្នុងមូលដ្ឋាន។

រដ្ឋបាលស្រុកបានប្រជុំពិនិត្យ ពិភាក្សានិងសម្រេចជ្រើសរើសគម្រោងប្រើប្រាស់មូលនិធិស្រុកចំនួន៥គម្រោងក្នុងនោះប្រើប្រាស់មូលនិធិស្រុកដែលទទួលបានពីការវិភាជន៍ជាប្រចាំឆ្នាំចំនួន២គម្រោង,ថវិកាដែលក្រសួងមហាផ្ទៃបានរំលែកចំនួន ២គម្រោង ដែលនិងត្រូវអនុវត្ត ក្នុងឆ្នាំ ២០២១ ខាងមុខនេះ។

### ៣.២.១. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល ឆ្នាំ ២០២១

**ក. កម្មវិធីផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលស្រុកបាធាយ**

- ការងារអត្រានុកូលដ្ឋាន
- នីត្យានុកូលកម្មលើវិញ្ញាបនបត្របណ្ដោះអាសន្ន,សៀវភៅគ្រួសារ, សៀវភៅស្នាក់នៅអត្តសញ្ញាណប័ណ្ណ និងឯកសារបញ្ជាក់ផ្សេងៗ
- លិខិតសុំអនុញ្ញាតច្បាប់ប្រកបអាជីវកម្ម

**ខ. កម្មវិធីផ្តល់សេវារដ្ឋបាលរបស់ការិយាល័យជំនាញ**

- បានផ្តល់សៀវភៅស្នាក់នៅ
- បានផ្តល់សៀវភៅស្នាក់នៅ ទុតិយការ
- បានផ្តល់សៀវភៅស្នាក់នៅគ្រួសារ
- បានផ្តល់សៀវភៅស្នាក់នៅគ្រួសារ ទុតិយការ
- ការងារថតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ពាក្យសុំបើកបន្ទប់ថៃទាំ
- ពាក្យបន្តសុពលភាពបន្ទប់ថៃទាំ
- ពាក្យបើកឱសថ និងឱសថស្ថានរងថ្មី
- ពាក្យសុំបន្តសុពលភាពឱ្យសថស្ថាន និងឱសថស្ថានរង
- ពាក្យសុំលំហែមាតុភាព
- សេវាសុរិយោដី។

### ៣.២.២. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា ឆ្នាំ ២០១៨

- លិខិតបទដ្ឋានគតិយុត្តរួមមានៈ
  - ដីកាស្តីពីការកំណត់តម្លៃសេវារដ្ឋបាលស្រុកបាធាយ ឆ្នាំ ២០១៧
  - សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារប្រតិបត្តិ នៃគណៈកម្មការត្រួតពិនិត្យគ្រឿងញៀន
  - សេចក្តីសម្រេចស្តីពីការតែងតាំងរដ្ឋទេយ្យករចំណូល, បុរេប្រទាន, ភ្នាក់ងារបើកផ្តល់
  - សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ
  - សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៃការកសាង

- ផែនការអភិវឌ្ឍ និងវិនិយោគ
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការលទ្ធកម្ម
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគម្រោង។

## ៣.៣. ក្របខណ្ឌតាមដាន និងវាយតម្លៃ

ក្រុមប្រឹក្សាស្រុកបានកំណត់ឱ្យមានក្របខណ្ឌតាមដាន និងវាយតម្លៃ ហើយក្រុមប្រឹក្សានិងត្រូវទទួលខុសត្រូវក្នុងការតាមដាន និងវាយតម្លៃជាប្រចាំឆ្នាំលើការអនុវត្តកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ដោយរាប់ទាំងផ្នែកនៃកម្មវិធីវិនិយោគដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់៖ ក្រុមប្រឹក្សាឃុំ, ការិយាល័យ ឬអង្គភាពជុំវិញស្រុក និង បណ្តាអង្គការសង្គមស៊ីវិល, ផ្នែកឯកជននានា ដែលប្រតិបត្តិក្នុងដែនដីរបស់រដ្ឋបាលស្រុកបាធាយ។

ក្នុងការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ ក្រុមប្រឹក្សាស្រុកបាធាយបានកំណត់ក្របខណ្ឌតាមដាន និងវាយតម្លៃ ដូចមានខាងក្រោម៖

**១. គម្រោងវិនិយោគ** របស់រដ្ឋបាលស្រុក/ឃុំ និងគម្រោងវិនិយោគរបស់ការិយាល័យជំនាញ

**២. កម្មវិធីប្រតិបត្តិការសេវា** របស់រដ្ឋបាលស្រុក/ឃុំ និងគម្រោងវិនិយោគរបស់ការិយាល័យជំនាញ

**៣. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្ត** របស់រដ្ឋបាលស្រុក និងលិខិតបទដ្ឋានគតិយុត្តរបស់ឃុំ។

ការតាមដាន និងវាយតម្លៃនេះ ផ្តោតលើគម្រោងដែលកំពុងដំណើរការ, គម្រោងមានកិច្ចសន្យាគាំទ្រ និងគម្រោងប្រើប្រាស់មូលនិធិរដ្ឋបាលនីមួយៗ ដោយត្រូវបានកំណត់ធាតុសំខាន់ៗ រួមមាន៖

- ឈ្មោះគម្រោង និងទីតាំងអនុវត្ត
- លទ្ធផលគម្រោងជាក់ស្តែងធៀប និងផែនការគម្រោង
- រយៈពេល
- តម្លៃគម្រោង
- អង្គភាពអនុវត្ត
- ភាគរយនៃការសម្រេចបាន។[39]

## ៣.៤. ការបែងចែកភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការតាមដាន និងវាយតម្លៃ

គណៈអភិបាលដោយមានការិយាល័យផែនការ និងគាំទ្រឃុំជាសេនាធិការត្រូវអនុវត្តការតាមដាន និងវាយតម្លៃរាល់ការអនុវត្តសកម្មភាពគម្រោងនានា ដោយផ្អែកតាមក្របខណ្ឌតាមដាន និងវាយតម្លៃដែលត្រូវបានកំណត់ដោយប្រើប្រាស់។

[39] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

ក្របខណ្ឌតាមដាន និងវាយតម្លៃ៖

១. តារាងតាមដានការអនុវត្តកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ

២. តារាងតាមដានការអនុវត្តកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលឃុំ

៣. តារាងតាមដានគម្រោងវិនិយោគ និងប្រតិបត្តិការសេវារបស់ការិយាល័យជំនាញ។

### ៣.៤.១. របាយការណ៍ស្តីពីលទ្ធផលតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ

នៅអំឡុងត្រីមាសទី៤ ប្រចាំឆ្នាំ គណៈអភិបាលដោយធ្វើកិច្ចសហការជាមួយតំណាងការិយាល័យ និងអង្គភាពនានាត្រូវរៀបចំនូវ**របាយការណ៍លទ្ធផលអនុវត្តកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ** ដោយបង្ហាញនូវសូចនាករសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- **គម្រោងវិនិយោគប្រើប្រាស់មូលនិធិស្រុក**៖បានរួចជាស្ថាពរ កំពុងអនុវត្ត និងមិនបានអនុវត្ត
- **គម្រោងស្រុកដែលមានការសន្យាគាំទ្រ** ៖ បានរួចជាស្ថាពរ កំពុងអនុវត្ត និងមិនបានអនុវត្ត
- **គម្រោងដែលបានអនុវត្ត មិនមានការសន្យាគាំទ្រ** ៖ បានរួចជាស្ថាពរ និងកំពុងអនុវត្ត។

បន្ទាប់ពីបានពិនិត្យកែសម្រួល និងរៀបចំរួចរាល់ គណៈអភិបាលនិងបន្តរាយការណ៍ជូនក្រុមប្រឹក្សាក្នុងកិច្ចប្រជុំណាមួយតាមការចាំបាច់ ។ ជាមួយនេះដែរ ក្នុងករណីចាំបាច់ក្រុមប្រឹក្សានិងផ្តល់នូវវិធានការណ៍ ឬ អនុសាសន៍ណែនាំសំខាន់ៗបន្ថែមលើវឌ្ឍន៍នភាព, សូចនាករ និងឧបសគ្គនានា ដែលជួបប្រទះក្នុងការអនុវត្តកម្មវិធីវិនិយោគ។ ក្រោយពីក្រុមប្រឹក្សាត្រួតពិនិត្យនិងឯកភាពរួចរាល់ជាស្ថាពរហើយគណៈអភិបាលនិងត្រូវបន្តចាត់ចែងរៀបចំឱ្យមានយន្តការផ្សព្វផ្សាយទៅកាន់អ្នកពាក់ព័ន្ធនានាស្របតាមការណែនាំឬការសម្រេចរបស់ក្រុមប្រឹក្សា។[40]

[40] របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើអត្ថបទនេះរួចមកឃើញថាការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយគឺជាផ្នែកមួយចាំបាច់បំផុតក្នុងការជំរុញ និងសម្រេចបាននូវទិសដៅនៃភាពជោគជ័យ។ ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ ស្របតាមគោលនយោបាយ ដូច្នេះប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ត្រូវអនុវត្តន៍នៅថ្នាក់ស្រុក តាមនីតិវិធីនៃច្បាប់។ សកម្មភាពការងារនៅក្នុងការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ ពិតជាមានភាពល្អប្រសើរ ដោយអនុវត្តទៅតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាលដែលបានខិតខំរៀបចំដាក់ចេញដើម្បីធ្វើការបម្រើប្រជាពលរដ្ឋដែលនេះបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់របស់ អភិបាលស្រុកបាធាយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមជនបទជាពិសេស គឺការអនុវត្តនូវគោលនយោបាយតាមបែបវិមជ្ឈការ និងវិសហមជ្ឈការក្នុងការគ្រប់គ្រងស្រុកបាធាយ ឃុំនៅតាមមូលដ្ឋានដែលជារដ្ឋបាលថ្នាក់ក្រោមជាតិមួយដ៏សំខាន់ដើម្បីជំរុញ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋតាមមូលដ្ឋានចូលរួមសកម្មភាពយ៉ាងពេញលេញដើម្បីបញ្ចេញមតិយោបល់ណាមួយ ក្នុងកាធ្វើសេចក្តីសម្រេចណាមួយពាក់ព័ន្ធនិងការអភិវឌ្ឍនៅក្នុងស្រុករបស់ខ្លួនក្នុងការជំរុញឱ្យមានលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សក្នុងមូលដ្ឋាន។ ម្យ៉ាងវិញទៀត ការគ្រប់គ្រងរដ្ឋបាលស្រុក ជាមួយមូលដ្ឋានគ្រឹះដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន មានស្ថេរភាព តម្លាភាពក្នុងសង្គមទាំងមូល។ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីសាលាស្រុកគ្រប់រូបបំពេញការងារបានយ៉ាងច្រើនក្នុងមូលដ្ឋានរបស់ខ្លួន បើទោះការធ្វើសកម្មភាពមិនបានពេញលេញ ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក៏ដោយ ក៏ស្រុកព្យាយាមផ្តល់ឱ្យ ទៅមានលិទ្ធភាពដែលអាចធ្វើទៅបានជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ស្រុកក៏មានវេទិការសាធារណៈសម្រាប់ឱ្យក្រុមប្រឹក្សាសង្កាត់ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានចូលរួមផ្តល់ជាព័ត៌មានឱ្យបានឆាប់រហ័ស និងធ្វើឱ្យស្រុកមានលទ្ធភាពកាន់តែខ្លាំង ក្នុងការឆ្លើយតបនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងស្រុកខណ្ឌ។

ទម្ងឹមនិងភាពរីកចម្រើន និងចំណុចល្អប្រសើខាងលលើនេះ ស្រុកក៏មានចំណុចអវិជ្ជមានដែលជៀសមិនផុតដូចជា ខ្វះខាតធនធានថវិការ ខ្វះខាតធនធានមនុស្សជំនាញ។

សរុបសេចក្តីមក យើងអាចធ្វើការសន្និដ្ឋានបានថា ថ្វីត្បិតមានសកម្មភាពអសកម្មមួយចំនួនយ៉ាងណាក៏ស្រុកនៅតែសម្រេចបាននូវប្រសិទ្ធភាព និងសមិទ្ធផលដូចជា សេវាផ្នែករដ្ឋបាល សន្តិសុខ តម្លាភាព សុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈដូច្នេះ (ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ នៅខេត្តកំពង់ចាមបច្ចុប្បន្ន) បានធ្វើឱ្យប្រជាពលរដ្ឋនៅក្នុងស្រុកទាំងមូលមានកម្រិតជីវភាពល្អប្រសើរទៅតាមដំណាក់ការនៃភាពកាន់តែរឹងមាំល្អប្រសើរ និងប្រជាពលរដ្ឋកាន់តែមានភាពយល់ដឹងពីតម្លៃនៃការចូលរួមសកម្មអភិវឌ្ឍន៍នៅមូលដ្ឋាន។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ និងសេចក្តីសន្និដ្ឋានខាងលើ ខ្ញុំបាទទាំងពីរនាក់មើលតាមស្ថានភាពជាក់ស្តែងថា ការគ្រប់គ្រងរដ្ឋបាលស្រុកបាធាយ និងអាជ្ញាធរដែលមានសមត្ថកិច្ច ជាពិសេសអាជ្ញាធរស្រុកបាធាយផ្ទាល់គឺជាផ្នែកមួយដែលចាំបាច់បំផុត ក្នុងការជំរុញឱ្យមានការអភិវឌ្ឍដើម្បីសម្រេចឱ្យបាននូវទិសដៅនៃភាពជោគជ័យ។ ការអភិវឌ្ឍលំនៅដ្ឋានហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដើម្បីផ្លាស់ប្តូរអោយមានភាពល្អប្រសើរ ជាពិសេសដើម្បីពង្រឹងលើការអនុវត្តនូវគោលនយោបាយ នៅថ្នាក់រដ្ឋបាលស្រុក នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- អាជ្ញាធរស្រុកគួរតែពង្រឹងផ្នែកសុខាភិបាលនៅស្រុកបាធាយបន្ថែម ដើម្បីឱ្យប្រជាជន មានភាពងាយស្រួលក្នុងការព្យាបាលជម្ងឺ។
- ពង្រឹងសមត្ថភាពការធ្វើការងារជាក្រុម បច្ចេកទេសកុំព្យូទ័រ និង បណ្តាញសង្គម
- ចំពោះម្ហូបអាហារ និងផលដំណាំ អាជ្ញាធរស្រុក គួរមានវិធានការអប់រំប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយ និងមិនឱ្យប្រើប្រាស់សារធាតុគីមីដែលបណ្តាយឱ្យប៉ះពាល់ដល់សុខភាព។
- សូមរាជរដ្ឋាអភិបាល អាជ្ញាធរខេត្ត ស្រុក និងឃុំ ជុំរុញការងារមួយ ផលិតផលមួយ ដើម្បីសម្រួលការរកទីផ្សារផលិតផល ចំណីអាហារ គ្រឿងសម្ភារៈ ក្នុងការបង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋ។
- សូមរាជរដ្ឋាភិបាល អាជ្ញាធរខេត្ត ស្រុក និងឃុំ បង្កើនការយល់ដឹងខ្ពស់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានអំពីបញ្ហាការចោលសំរាម និងគ្មានអនាម័យនៅក្នុងបរិស្ថាន ដើម្បីសុខភាពរបស់ប្រជាពលរដ្ឋក្នុងការរស់នៅ។
- បើកទិវាសាធារណៈឱ្យបានញឹកញាប់ ដើម្បីទទួលបាននូវរាល់បញ្ហាប្រឈមនានា ដែលកើតមានឡើងនៅក្នុងស្រុក រួចរកដំណោះស្រាយជូនប្រជាពលរដ្ឋឱ្យបានសមស្រប។
- រាជរដ្ឋាភិបាល ក៏ដូចជាក្រសួង ស្ថាប័ននានាដែលមានសមត្ថកិច្ច មេត្តារៀបចំបង្កើតតុលាការរដ្ឋបាលដើម្បីដោះស្រាយបញ្ហាវិវាទរដ្ឋបាលនៅក្នុងស្រុក។
- សូមរាជរដ្ឋាភិបាល បង្កើនយន្តការល្អៗក្នុងការអនុវត្តគោលនយោបាយនៅស្រុកបាធាយឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅក្នុងស្រុកឱ្យរឹតតែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

❖ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត

➢ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៨
➢ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ២០១៩
➢ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកប្រឹក្សាខណ្ឌ ឆ្នាំ២០០៨
➢ អនុក្រឹត្យលេខ២៤០ អនក្រ ប.ក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការផ្ទេរប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
➢ អនុក្រឹត្យលេខ១៩ អនក្រ ប.ក ចុះថ្ងៃទី០៨ ខែកម្ភៈ ឆ្នាំ ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
➢ អនុក្រឹត្យលេខ១៨៤ អនក្រ ប.កចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី មុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
➢ អនុក្រឹត្យលេខ២១៦ អនក្រ ប.កចុះថ្ងៃទី១៤ ធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលខេត្ត។

❖ សៀវភៅតែងនិពន្ធ

➢ នីតិរដ្ឋបាលទូទៅ រៀបរៀងដោយបណ្ឌិត សាយ បូរី ២០០១
➢ សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក ឆ្នាំ២០១០
➢ សៀវភៅ សមត្ថ និងរបៀបរបបការងារ នៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១១
➢ សៀវភៅ អភិបាលកិច្ចល្អ បោះពុម្ពលើកទី៤ ឆ្នាំ២០១៣
➢ នីតិមុខងារសាធារណៈ រៀបរៀងដោយ បណ្ឌិត ហៀង សាង ឆ្នាំ២០១៨
➢ សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រ ក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ

❖ របាយការណ៍ស្រុក

➢ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកបាធាយអាណត្តិទី៣(២០១៨-២០២២)
➢ របាយការណ៍កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលស្រុកបាធាយ (២០២២-២០២៤)

❖ គេហទំព័រ

- គេហទំព័រ https://kampongthom.gov.kh/12733/
- គេហទំព័រ https://kampongthom.gov.kh/4096/
- គេហទំព័រ https://www.mcs.gov.kh/?p=20492
- គេហទំព័រ https://kampongthom.gov.kh/6295/

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

- ឧបសម្ព័ន្ធទី១៖ ផែនទីស្រុកបាធាយ ខេត្តកំពង់ចាម
- ឧបសម្ព័ន្ធទី២៖ ទិដ្ឋភាពសាលាស្រុកបាធាយ និងការិយាល័យច្រកចេញចូលតែមួយ
- ឧបសម្ព័ន្ធទី៣៖ អភិបាលខេត្តកំពង់ចាមនិងអភិបាលស្រុកបាធាយអញ្ជើញចុះពិនិត្យមើលស្ថានភាពសណ្តាប់ធ្នាប់ស្រុកបាធាយ
- ឧបសម្ព័ន្ធទី៤៖ សកម្មភាព នៃរបៀបរបបប្រជុំការងារ សាលាស្រុកបាធាយ
- ឧបសម្ព័ន្ធទី៥៖ សកម្មភាព នៃការប្រជុំផ្សព្វផ្សាយពីស្ថានភាពអាកាសធាតុ និងការប្រើប្រាស់ទឹកធ្វើស្រែនារដូវប្រាំង
- ឧបសម្ព័ន្ធទី៦៖ សកម្មភាពទស្សកិច្ចសិក្សា នៅក្នុងមន្ទីរពេទ្យបង្អែកបាធាយ ខេត្តកំពង់ចាម ដែលជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាលដើម្បីផ្លាស់ប្តូរបទពិសោធន៍ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ
- ឧបសម្ព័ន្ធទី៧៖ សកម្មភាពកងកម្លាំង នៃអធិការដ្ឋាននគរបាលស្រុកបាធាយ
- ឧបសម្ព័ន្ធទី៨៖ ការិយាល័យច្រកចេញចូលតែមួយ ស្រុកបាធាយ
- ឧបសម្ព័ន្ធទី៩៖ សកម្មភាពផ្តល់សេវាជូនប្រជាពលរដ្ឋរបស់មន្ត្រី នៃការិយាល័យច្រកចេញចូលតែមួយស្រុកបាធាយ
- ឧបសម្ព័ន្ធទី១០៖ សកម្មភាពប្រជាពលរដ្ឋមករកសេវាសាធារណៈ នៅការិយាល័យច្រកចេញចូលតែមួយស្រុកបាធាយ
- ឧបសម្ព័ន្ធទី១១៖ ទិដ្ឋភាពតាមដងផ្លូវជាតិគមនាគមន៍ ខេត្តកំពង់ចាម ក្នុងនោះស្រុកបាធាយស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៦

## ២. ឧបសម្ព័ន្ធគតិយុត្ត

- ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៨
- ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០១៩
- ឧបសម្ព័ន្ធទី៣៖ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុកប្រឹក្សាខណ្ឌ ឆ្នាំ២០០៨

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១ ផែនទីស្រុកបាធាយ ខេត្តកំពង់ចាម



# ផែនទី រដ្ឋបាល និង ហេដ្ឋារចនាសម្ព័ន្ធ ស្រុកបាធាយ ខេត្តកំពង់ចាម

Administration and Infrastructure of Batheay District (0301), Kampong Cham Province



## ឧបសម្ព័ន្ធទី២ ទិដ្ឋភាពសាលាស្រុកបាធាយ និងការិយាល័យច្រកចេញចូលតែមួយ









## ឧបសម្ព័ន្ធទី៣ អភិបាលខេត្តកំពង់ចាម និងអភិបាលស្រុកបាធាយ អញ្ជើញចុះពិនិត្យមើលស្ថានភាពសណ្តាប់ធ្នាប់ស្រុកបាធាយ









## ឧបសម្ព័ន្ធទី៤ សកម្មភាព នៃរបៀបរបបប្រជុំការងារ សាលាស្រុកបាធាយ





## ឧបសម្ព័ន្ធទី៥ សកម្មភាព នៃការប្រជុំផ្សព្វផ្សាយពីស្ថានភាពអាកាសធាតុ និងការប្រើប្រាស់ទឹកធ្វើស្រែនារដូវប្រាំង





ឯកឧត្តម ថោ ជេដ្ឋា រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយមបានចុះទៅកាន់នៅស្រុកបាធាយ ខេត្តកំពង់ចាម







បន្ទាប់មក ឯកឧត្តមរដ្ឋលេខាធិការ និងក្រុមការងារក៏បានបន្តចុះពិនិត្យការបង្កបង្កើនផលស្រូវប្រាំងនៅក្នុងប្រព័ន្ធធារាសាស្ត្រ អាងទឹកឫស្សីព្រះ ស្ថិតក្នុងឃុំមេព្រីង ស្រុកបាធាយ។ នៅក្នុងប្រព័ន្ធនេះ ប្រជាកសិករបានធ្វើការបង្កបង្កើនផលស្រូវប្រាំងលើផ្ទៃដីចំនួន ៤៨៦ហិកតា ហើយស្ថានភាពទឹកដែលមាននៅក្នុងប្រព័ន្ធ គឺអាចធានាផ្គត់ផ្គង់បានទាំងស្រុង។



## ឧបសម្ព័ន្ធទី៦ សកម្មភាពទស្សកិច្ចសិក្សា នៅក្នុងមន្ទីរពេទ្យបង្អែកបាធាយ ខេត្ត កំពង់ចាម ដែលជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាលដើម្បី ផ្លាស់ប្តូរបទពិសោធន៍ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ






លោកវេជ្ជបណ្ឌិត ហៃ ទ្បេសុន ប្រធានមន្ទីរពេទ្យខេត្តកោះកុង បានដឹកនាំប្រតិភូអញ្ជើញទស្សកិច្ចសិក្សា

នៅមន្ទីរពេទ្យបង្អែកបាធាយក្នុងវិស័យសុខាភិបាល ដើម្បីផ្លាស់ប្តូរបទពិសោធន៍




សកម្មភាពនៃការចុះបំពេញទស្សនកិច្ចតាមផ្នែកនីមួយៗ ដើម្បីផ្លាស់ប្តូរបទពិសោធន៏នៃជំនាញវិជ្ជាជីវៈ









# ឧបសម្ព័ន្ធទី៧ សកម្មភាពកងកម្លាំង នៃអធិការដ្ឋាននគរបាលស្រុកបាធាយ











កម្លាំងរបស់អធិការដ្ឋាននគរបាលស្រុកបាធាយចុះសម្រួលចរាចរណ៍នៅចំណុចសំខាន់ៗ លើផ្លូវជាតិលេខ៦ ក្នុងភូមិសាស្ត្រស្រុកបាធាយ ដែលមានប្រជាពលរដ្ឋឆ្លងកាត់ច្រើន។



# ឧបសម្ព័ន្ធទី៨ ការិយាល័យច្រកចេញចូលតែមួយ ស្រុកបាធាយ






សកម្មភាពនៃការចូលរួមប្រជុំក្រុមប្រឹក្សាស្រុកនៅការិយាល័យប្រជាពលរដ្ឋស្រុកបាធាយ លើកទី៣៧ អាណត្តិទី៣ ថ្ងៃចន្ទទី០៤ខែកក្កដាឆ្នាំ២០២២ ក្រោមអធិបតីភាពលោក ចេង វ័ន្ទ ប្រធានក្រុមប្រឹក្សាស្រុកបាធាយ

## ឧបសម្ព័ន្ធទី៩ សកម្មភាពផ្ដល់សេវាជូនប្រជាពលរដ្ឋរបស់មន្រ្តី នៃការិយាល័យច្រកចេញចូលតែមួយស្រុកបាធាយ





# ឧបសម្ព័ន្ធទី១០ សកម្មភាពប្រជាពលរដ្ឋមករកសេវាសាធារណៈ នៅការិយាល័យច្រកចេញចូលតែមួយស្រុកបាធាយ









## ឧបសម្ព័ន្ធទី១១ ទិដ្ឋភាពតាមដងផ្លូវជាតិគមនាគមន៍ ខេត្តកំពង់ចាម ក្នុងនោះ ស្រុកបាធាយស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៦



ផ្លូវជាតិលេខ៦



ផ្លូវជាតិលេខ៧



ផ្លូវព្រះសីហនុ (មាត់ទន្លេ)



ផ្លូវលេខ៧១

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ១៦.-**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខ-ជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.-**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម :

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបដដែលនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

**មាត្រា ១៣៩.-**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.-**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

-ចំណូលរបស់ក្រុមប្រឹក្សាស្រុក បានមកពីពន្ធ ឈ្នួល និងកម្រៃ ដែលត្រូវចែករំលែករវាងក្រុមប្រឹក្សាស្រុក ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក

-អំណោយស្ម័គ្រចិត្ត

-ប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬ អនុក្រឹត្យ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ។

ពន្ធ និងអាករនៅថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីច្បាប់សារពើពន្ធ ។

**មាត្រា ២៤៧.–**

ចំណូលពីថ្នាក់ជាតិ រួមមាន :

-ចំណូលចែករំលែក

-មូលនិធិផ្ទេរពីថវិការដ្ឋ និង

-ថ្លៃសេវា បានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៤៨.–**

ការបែងចែកចំណូលដែលបានមកពីថ្លៃចេញអាជ្ញាប័ណ្ណអាជីវកម្ម ពីកម្រៃសេវានិងពីចំណូលមិនមែនសារពើពន្ធដទៃទៀតរវាងស្រុក ឃុំ និងសង្កាត់ក្នុងស្រុក ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២៤៩.–**

ក្រុមប្រឹក្សាមានសិទ្ធិទទួលពីចំណូលជាតិនូវមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌនិងមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ។

ការផ្ទេរមូលនិធិពីថវិការដ្ឋ រួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌនិងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងជាដំណាក់កាលៗ សម្រាប់ឆ្នាំនីមួយៗ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភាឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៥០៥.៥៩៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខៈ ៥៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជីនកេន**

# ព្រះរាជក្រម

នស/រកម/០១១៩/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី[illegible] ខែមករា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤ ព្រមទាំងត្រូវបានដោយក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៩៨/០០១/២០១៩ កបធ.ច ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
## ស្តីពី
## វិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រាមួយ.-**

មាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ១៨.- ថ្មី**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ ដូចខាងក្រោម ៖

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃប្រាំពីរ (២៧) រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីដប់ប្រាំ (១៥) រូប ដល់ម្ភៃប្រាំពីរ (២៧) រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីដប់មួយ (១១) រូប ដល់ម្ភៃមួយ (២១) រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីដប់មួយ (១១) រូប ដល់ម្ភៃមួយ (២១) រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០) ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៩

ចរ.ម. ១៩០១-០១៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បានអនុម័តកាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការបោះឆ្នោតជ្រើសរើស

# ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត

# ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំ ការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការបោះឆ្នោតអសកល ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយដែលក្នុងច្បាប់នេះហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ២.–**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

**មាត្រា ៣.–**

បទប្បញ្ញត្តិដូចមានចែងនៅក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកមកអនុវត្តសម្រាប់កំណត់ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ។

**មាត្រា ៤.–**

សមាជិកក្រុមប្រឹក្សាត្រូវជ្រើសរើសឡើង ដោយការបោះឆ្នោតអសកល មិនចំពោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

**មាត្រា ៥.–**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើតែមួយថ្ងៃ នៅថ្ងៃអាទិត្យណាមួយ ។

កាលបរិច្ឆេទជាក់ស្តែងនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦.–**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមប្រឹក្សាណាមួយលាលែងពីមុខតំណែង ឬត្រូវបានរំលាយក្នុងកំឡុងពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា គណៈកម្មាធិការជាតិរៀបចំការ

កំណត់ក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០)ថ្ងៃមុនថ្ងៃបោះឆ្នោត ដោយអនុលោមតាមមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ៩១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩២.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៨

នស/រកម.០៥០៨.០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខៈ ៥៥១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**